ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## ឯកសារស្តីពីការពន្យារពេលមួយឆ្នាំនៃ ផអ៣

# ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤

# របស់ គ.ជ.អ.ប

ខែមករា ឆ្នាំ២០១៤

# អារម្ភកថា

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ខែឧសភា ឆ្នាំ២០០៨) ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ខែឧសភា ឆ្នាំ២០០៩) ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣ (ខែឧសភា ឆ្នាំ២០១៣) ការរៀបចំនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ខែមិថុនា ឆ្នាំ២០១០) និងការអនុម័តនូវផែនការអនុវត្តបីឆ្នាំដំបូងនៃកម្មវិធីជាតិ (ខែមិថុនា ឆ្នាំ២០១០) បានបង្ហាញឱ្យឃើញនូវឆន្ទៈដ៏ច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជាអំពីកំណែទម្រង់ផ្នែកគោលនយោបាយ រដ្ឋបាល និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងអំឡុងពេលនៃឆ្នាំ២០១៣កន្លងមកនេះ ការអនុវត្ត ផអ៣ សម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនគួរជាទីមោទនៈ។ ជាមួយគ្នានេះដែរ ស្ថានភាពហិរញ្ញវត្ថុរបស់ ផអ៣ នាពេលបច្ចុប្បន្នមានភាពល្អប្រសើរជាងមុន ហើយការគាំទ្រមូលនិធិសម្រាប់រយៈពេលមធ្យមកាន់តែមានភាពច្បាស់លាស់ផងដែរ។ ក្នុងអំឡុងពេលពីឆ្នាំ២០១៣ដល់២០១៥ សហភាពអឺរ៉ុប (EU) និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (Sida) ដែលបានរួមចំណែកផ្ទាល់ទៅក្នុងមូលនិធិកញ្ចប់រួមរបស់ ផអ៣ តាមរយៈការផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនិងផ្នែករដ្ឋបាល រំពឹងថានឹងមានមូលនិធិគាំទ្រចំនួនប្រមាណ ២០លានអឺរ៉ូ។ ក្នុងឆ្នាំនេះដែរ ទីភ្នាក់ងារអភិវឌ្ឍន៍និងកិច្ចសហប្រតិបត្តិការរបស់ប្រទេសស្វីស (SDC) បានយល់ព្រមចូលរួមចំណែកផ្តល់មូលនិធិរបស់ខ្លួនក្នុងមូលនិធិកញ្ចប់រួមរបស់ ផអ៣ ផងដែរ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសង្ឃឹមថានឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ថ្មីទាំងពីរគឺ EU និង SDC ក៏ដូចជាការបន្តទទួលបាននូវការគាំទ្រជាវិជ្ជមាននានា អនុសាសន៍ និងកិច្ចសហប្រតិបត្តិការដែលធ្លាប់មានកន្លងមកជាមួយ Sida។

ទាក់ទងនឹងការកសាងសមត្ថភាព វឌ្ឍនភាពគួរឱ្យកត់សម្គាល់ដែលសម្រេចបាន គឺការរៀបចំ និងដាក់ឱ្យអនុវត្តនូវនីតិវិធីអនុវត្តការងារ និងសេចក្តីណែនាំនានារបស់ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីរដ្ឋបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ បច្ចុប្បន្ននេះ ប្រព័ន្ធជាច្រើនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។ ការផ្តល់សេវាសម្របសម្រួល និងអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក៏កំពុងត្រូវបានបន្តអនុវត្តព្រមគ្នាជាមួយនឹងកិច្ចដំណើរនៃការអភិវឌ្ឍស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ វគ្គបណ្តុះបណ្តាលជាច្រើនក៏ត្រូវបានអនុវត្តនៅតាមអនុកម្មវិធីនានានៃ ផអ៣។

ចំពោះកិច្ចដំណើរការនៃការផ្ទេរមុខងារ ក្រសួង ស្ថាប័នអាទិភាពចំនួន៥បានរៀបចំបញ្ចប់នូវរបាយការណ៍ស្តីពីបញ្ជីវិភាគមុខងាររបស់ខ្លួន ដើម្បីឈានទៅកំណត់នូវមុខងារ និងធនធាននានាដែលត្រូវផ្ទេរទៅឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិជាលក្ខណៈអចិន្ត្រៃយ៍ ឬជាលក្ខណៈសាកល្បង។ កិច្ចដំណើរការនេះបានផ្តល់នូវមេរៀន និងបទពិសោធន៍ជាច្រើន ហើយបច្ចុប្បន្ននេះ ការសាកល្បងស្តីពីការផ្ទេរមុខងារចំនួនពីរពាក់ព័ន្ធនឹងសុខភាព និងអនាម័យជនបទកំពុងត្រូវបានរៀបចំឡើង។ ក្នុងឆ្នាំ២០១៣នេះដែរ មានការសិក្សាជាច្រើនត្រូវបានអនុវត្តក្នុងគោលបំណងសិក្សាស្វែងយល់ និងបកស្រាយឱ្យបានច្បាស់លាស់អំពីមុខងារជាអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការរៀបចំលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការលើកកម្ពស់តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព។

ពាក់ព័ន្ធនឹងកិច្ចការហិរញ្ញវត្ថុវិញ លិខិតបទដ្ឋានគតិយុត្តស្តីពីប្រព័ន្ធមូលនិធិក្រុង ស្រុក និងការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុកត្រូវបានរៀបចំបញ្ចប់ និងដាក់ឱ្យអនុវត្ត។ ជាមួយគ្នានេះដែរ គម្រោងអភិវឌ្ឍន៍ក្រុង ស្រុកក៏ត្រូវបានកំណត់ និងរៀបចំ។ ក្នុងន័យនេះ មូលនិធិក្រុង ស្រុកនឹងត្រូវអនុវត្តយ៉ាងពេញលេញចាប់ពីឆ្នាំ២០១៤តទៅ។ យើងសង្ឃឹមជឿជាក់ថា ការអនុវត្តមូលនិធិក្រុង ស្រុកនឹងផ្តល់លទ្ធភាពឱ្យរដ្ឋបាលក្រុង ស្រុកអនុវត្តសកម្មភាពអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាពនិងមានតម្លាភាព ក៏ដូចជាការបង្ហាញឱ្យឃើញពីសមត្ថភាពនិងសក្តានុពលរបស់ក្រុង ស្រុកក្នុងការចូលរួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ពាក់ព័ន្ធនឹងការពង្រឹងស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួន មានលិខិតបទដ្ឋានគតិយុត្តសំខាន់ៗចំនួនពីរត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តក្នុងនោះរួមមាន៖ ក) ច្បាប់ស្តីពីការធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី និងខ) អនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ លិខិតបទដ្ឋានគតិយុត្តទាំងពីរនេះបានផ្តល់នូវក្របខ័ណ្ឌគតិយុត្តដល់រាជរដ្ឋាភិបាលក្នុងការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ពាក់ព័ន្ធនឹងការងារគណនេយ្យភាព ផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គមត្រូវបានរៀបចំតាក់តែងដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអង្គការសង្គមស៊ីវិលនានា ហើយត្រូវបានអនុម័តដោយ គ.ជ.អ.ប នាខែសីហា ឆ្នាំ២០១៣។ ផែនការយុទ្ធសាស្ត្រនឹងត្រូវអនុវត្តរួមគ្នាដោយរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនានា។ ផែនការយុទ្ធសាស្ត្រនេះ មានគោលបំណងលើកកម្ពស់លទ្ធភាពទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការអនុវត្តការងារ និងការប្រើប្រាស់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំបង្កើតនូវកិច្ចដំណើរការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋលើការចំណាយនិងការផ្តល់សេវាសាធារណៈ ព្រមទាំងបង្កើតនូវយន្តការប្រាស្រ័យទាក់ទងរវាងរដ្ឋបាលមូលដ្ឋាន សហគមន៍ និងប្រជាពលរដ្ឋក្នុងការកំណត់ និងឯកភាពទៅលើវិធានការនានាសម្រាប់ការកែលំអការផ្តល់សេវានានា។ ផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម ផ្តោតជាសំខាន់លើការប្រាស្រ័យទាក់ទងរវាងរដ្ឋបាលមូលដ្ឋានជាមួយនឹងប្រជាពលរដ្ឋ សហគមន៍ និងអង្គការសង្គមស៊ីវិលប្រកបដោយការស្ថាបនា។ នៅចុងឆ្នាំ២០១៣ សេចក្តីព្រាងឧបករណ៍សំខាន់ៗនានាសម្រាប់សម្របសម្រួលដល់យន្តការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងសម្រាប់ការផ្តល់នូវព័ត៌មានសំខាន់ៗដល់ប្រជាពលរដ្ឋត្រូវបានរៀបចំ។

ជាមួយនឹងសមិទ្ធផលជាច្រើនត្រូវបានសម្រេចដូចបានរៀបរាប់ខាងលើ ប៉ុន្តែការអនុវត្តជាក់ស្តែងនៅមានភាពយឺតយ៉ាវបើប្រៀបធៀបនឹងគម្រោងផែនការទូទៅរបស់ ផអ៣។ ទោះបីជាការរៀបចំតាក់តែង ផអ៣ មានលក្ខណៈល្អប្រសើរក្តី ប៉ុន្តែការកំណត់ចិរវេលាសម្រាប់ការអនុវត្តផែនការនេះមានមហិច្ឆតាយ៉ាងខ្លាំង។ ជាក់ស្តែង ការសិក្សាវាយតម្លៃនិងការចាប់ផ្តើមអនុវត្តផែនការនេះមានភាពយឺតយ៉ាវជាងការរំពឹងទុក និងមានការផ្លាស់ប្តូរជាច្រើនក្នុងការរៀបចំ និងអនុវត្តនូវសកម្មភាពជាគន្លឹះមួយចំនួនដូចជា កិច្ចដំណើរផ្ទេរមុខងារ ការរៀបចំឧបករណ៍វិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក និងការកែសម្រួលកិច្ចដំណើរការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាដើមដែលតម្រូវឱ្យមានការពិភាក្សាឡើងវិញជាច្រើនលើកច្រើនសារ។ ក្នុងការដោះស្រាយបញ្ហាទាំង

នេះ យើងបានចំណាយពេលវេលា និងធនធានយ៉ាងច្រើនក្នុងការពិនិត្យមើលឡើងវិញលើការអនុវត្ត ដើម្បីកំណត់នូវអាទិភាពនានាដែលត្រូវអនុវត្តក្នុងរយៈពេលនៃការពន្យារពេល ផអ៣ រយៈពេលមួយឆ្នាំ។ ឯកសារពន្យារពេល ផអ៣ នេះបានកំណត់នូវអាទិភាពជាគន្លឹះចំនួន១៣ដែលត្រូវសម្រេចឱ្យបាននៅក្នុងឆ្នាំ២០១៤។

ជារួម ប្រសិទ្ធភាព និងជោគជ័យនៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤ គឺអាស្រ័យលើការប្រឹក្សាយោបល់យ៉ាងពេញលេញ និងកិច្ចសហប្រតិបត្តិការក្នុងស្មារតីទទួលខុសត្រូវខ្ពស់នៅក្នុងក្របខ័ណ្ឌនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិតទាំងអស់នៃរាជរដ្ឋាភិបាលទាំងមូល។ យើងនឹងបន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដើម្បីធានាថាកិច្ចដំណើរការនៃកំណែទម្រង់នេះផ្តល់នូវផលប្រយោជន៍យ៉ាងពិតប្រាកដដល់ប្រជាពលរដ្ឋកម្ពុជាទាំងមូល។

ក្នុងនាម គ.ជ.អ.ប និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិកទាំងអស់នៃ គ.ជ.អ.ប លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួង ស្ថាប័នអនុវត្តអនុកម្មវិធី និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាដែលបានរួមចំណែកយ៉ាងសកម្មក្នុងការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៣ របស់ គ.ជ.អ.ប ហើយខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឆ្នាំ២០១៤ នឹងនាំមកនូវសមិទ្ធផលធំធេងបន្ថែមទៀតសម្រាប់យើងទាំងអស់គ្នា។

រាជធានីភ្នំពេញថ្ងៃទី...០៥...ខែ...កុម្ភៈ...ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**ស ខេង**

# មាតិកា


**អារម្ភកថា** ..... i

**មាតិកា** ..... iv

**បញ្ជីតារាង** ..... vi

**បញ្ជីរូបភាព** ..... vi

**បញ្ជីអក្សរកាត់** ..... vii

**វាក្យស័ព្ទ និងនិយមន័យ** ..... viii

**សេចក្តីផ្តើម** ..... ១

**ក. អាទិភាពសំខាន់ៗក្នុងឆ្នាំ២០១៤** ..... ១

**ខ. ថវិកានៃ ផ.ស.ថ ឆ្នាំ២០១៤** ..... ៦

ខ.១ ផែនការចំណាយ ..... ៦

ខ.២ ប្រភពមូលនិធិ ..... ៧

ខ.៣ សមតុល្យ ..... ៨

**គ. ជំនួយបច្ចេកទេស** ..... ៨

**ជំពូកទី១ ÷ ការរៀបចំគោលនយោបាយ និងការសម្របសម្រួលកម្មវិធី (អនុកម្មវិធីទី១)** ..... **១១**

១.១. សេចក្តីផ្តើម ..... ១១

១.២. លទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី១ ..... ១២

១.៣. ថវិការបស់អនុកម្មវិធីទី១ ..... ១៦

**ជំពូកទី២ ÷ ការរៀបចំបុគ្គលិក ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រហេដ្ឋារចនាសម្ព័ន្ធក្រុង ស្រុក (អនុកម្មវិធីទី២)** ..... **១៨**

២.១. សេចក្តីផ្តើម ..... ១៨

២.២. លទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី២ ..... ១៨

២.៣. ថវិការបស់អនុកម្មវិធីទី២ ..... ២១

**ជំពូកទី៣ ÷ ការគ្រប់គ្រងធនធានមនុស្សរដ្ឋបាលថ្នាក់ក្រោមជាតិ (អនុកម្មវិធីទី៣)** ..... **២២**

៣.១. សេចក្តីផ្តើម ..... ២២

៣.២. លទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៣ ..... ២២

៣.៣. ថវិការបស់អនុកម្មវិធីទី៣ ..... ២៣

**ជំពូកទី៤ ÷ ធនធានរដ្ឋបាលថ្នាក់ក្រោមជាតិ (អនុកម្មវិធីទី៤)** ..... **២៤**

៤.១. សេចក្តីផ្តើម ..... ២៤

៤.២. លទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៤ ..... ២៥

៤.៣. ថវិការបស់អនុកម្មវិធីទី៤ ..... ២៦

**ជំពូកទី៥ ÷ ប្រព័ន្ធកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (អនុកម្មវិធីទី៥)..... ២៨**

៥.១. សេចក្តីផ្តើម ..... ២៨

៥.២. លទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៥..... ២៨

៥.៣. ថវិការបស់អនុកម្មវិធីទី៥..... ២៩

**ជំពូកទី៦ ÷ សមត្ថភាពរបស់សមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (អនុកម្មវិធីទី៦)..... ៣០**

៦.១. សេចក្តីផ្តើម ..... ៣០

៦.២. លទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៦ ..... ៣០

៦.៣. ថវិការបស់អនុកម្មវិធីទី៦ ..... ៣១

**ជំពូកទី៧ ÷ លទ្ធផលរំពឹងទុករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ..... ៣២**

៧.១. សេចក្តីផ្តើម ..... ៣២

៧.២. លទ្ធផលរំពឹងទុក និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ..... ៣២

**ឧបសម្ព័ន្ធ..... ៣៤**

# បញ្ជីតារាង

តារាងទី១ ៖ ទិដ្ឋភាពរួមនៃគម្រោងថវិកាឆ្នាំ២០១៤ ........ ៧
តារាងទី២ ៖ សារពើពន្ធដែលបម្រុងផ្ទេរឆ្នាំ២០១៤ ........ ៧
តារាងទី៣ ៖ មូលនិធិតាមប្រភពរបស់ ផ.ស.ថ ឆ្នាំ២០១៤ ........ ៨
តារាងទី៤ ៖ ជំនួយបច្ចេកទេស និងមន្ត្រីកិច្ចសន្យា ........ ១០
តារាងទី៥ ៖ លទ្ធផលរំពឹងទុក និងថវិការបស់អនុកម្មវិធីទី១ ........ ១៦
តារាងទី៦ ៖ លទ្ធផលរំពឹងទុក និងថវិការបស់អនុកម្មវិធីទី២ ........ ២១
តារាងទី៧ ៖ លទ្ធផលរំពឹងទុក និងថវិការបស់អនុកម្មវិធីទី៣ ........ ២៣
តារាងទី៨ ៖ លទ្ធផលរំពឹងទុក និងថវិការបស់អនុកម្មវិធីទី៤ ........ ២៦
តារាងទី៩ ៖ លទ្ធផលរំពឹងទុក និងថវិការបស់អនុកម្មវិធីទី៥ ........ ២៩
តារាងទី១០ ៖ លទ្ធផលរំពឹងទុក និងថវិការបស់អនុកម្មវិធីទី៦ ........ ៣១
តារាងទី១១ ៖ លទ្ធផលរំពឹងទុក និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ........ ៣២
តារាងទី១២ ៖ ចំណុចដៅគន្លឹះសម្រាប់ឆ្នាំ២០១៤-២០១៨ ........ ៣៤

# បញ្ជីប្រអប់

ប្រអប់ទី១ ៖ និន្នាការមូលនិធិកញ្ចប់រួម ........ ៦
ប្រអប់ទី២ ៖ សមិទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី១ ........ ១១
ប្រអប់ទី៣ ៖ សមិទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី២ ........ ១៨
ប្រអប់ទី៤ ៖ សមិទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៣ ........ ២២
ប្រអប់ទី៥ ៖ សមិទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៤ ........ ២៤
ប្រអប់ទី៦ ៖ សមិទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៥ ........ ២៨
ប្រអប់ទី៧ ៖ សមិទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៦ ........ ៣០

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| គ.ជ.អ.ប | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| ផអ៣ | ផែនការអនុវត្តរយៈពេលបីឆ្នាំនៃកម្មវិធីជាតិ |
| ផ.ស.ថ | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| គ.ក.ស.ក | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| គ.ក.ន.ក | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| Basket | មូលនិធិកញ្ចប់រួមគាំទ្រដោយ Sida, SDC និង EU |
| In kind | ការចូលរួមចំណែកមិនមែនជាថវិកាដូចជា ការផ្តល់ជំនួយបច្ចេកទេសមកគាំទ្រការងារ ផអ៣ ជាដើម |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| Sida (ស៊ីដា) | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែដ |
| EU | សហភាពអឺរ៉ុប |
| EU-SPACE | កម្មវិធីគាំទ្រដោយសហគមន៍អឺរ៉ុបដើម្បីគាំទ្រការចូលរួមរបស់សង្គមស៊ីវិល |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADB-PPTA | គម្រោងជំនួយបច្ចេកទេសសម្រាប់ការរៀបចំគម្រោង គាំទ្រដោយ ADB |
| ADB-DPFSM | កម្មវិធីស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងការផ្តល់សេវាសាធារណៈបែបវិមជ្ឈការ គាំទ្រដោយ ADB |
| ADB-TS-PRSDP | គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប គាំទ្រដោយ ADB |
| SDC | ទីភ្នាក់ងារអភិវឌ្ឍន៍ និងសហប្រតិបត្តិការរបស់ប្រទេសស្វីស |
| WB | ធនាគារពិភពលោក |
| WB-OWSO | គម្រោងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ គាំទ្រដោយធនាគារពិភពលោក |
| WB-LASED | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គាំទ្រដោយធនាគារពិភពលោក |
| UNICEF | មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |
| UN-Women | គម្រោងលើកកម្ពស់សិទ្ធិស្ត្រី និងអនុសញ្ញា ស៊ី-ដ របស់យូអិន |
| UNDP/ACES | គម្រោងលើកកម្ពស់សេវារបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិគាំទ្រដោយយូអិនឌីភី |
| UNDP/SNC Scale-up | គម្រោងបញ្ជ្រាបយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុក្នុងដំណើរការកសាងផែនការ និងថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ គាំទ្រដោយយូអិនឌីភី |
| UNFPA | មូលនិធិប្រជាពលរដ្ឋរបស់អង្គការសហប្រជាជាតិ |
| UNCDF-LGCCII | គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ គាំទ្រដោយមូលនិធិសម្រាប់អភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ |
| JICA-PILAC 2 | គម្រោងសម្រាប់កិច្ចអភិវឌ្ឍសមត្ថភាពក្នុងការអនុវត្តច្បាប់រៀបចំអង្គការ គាំទ្រដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសជប៉ុន |
| AusAid | កម្មវិធីជំនួយបរទេសរបស់រដ្ឋាភិបាលអូស្ត្រាលី |
| SPs | អនុកម្មវិធីនានានៃ ផអ៣ ដូចជា SP1 គឺជាអនុកម្មវិធីទី១ |

## វាក្យស័ព្ទ និងនិយមន័យសំខាន់ៗ

| | |
|---|---|
| **ផលប៉ះពាល់** | ការជះឥទ្ធិពលជាវិជ្ជមាន ឬជាអវិជ្ជមាន ដោយផ្ទាល់ ឬដោយប្រយោលដែលផ្ដើមចេញពីកិច្ចអន្តរាគមន៍នៃការអភិវឌ្ឍមួយមានលក្ខណៈដោយផ្ទាល់ ឬដោយប្រយោល ដោយចេតនា ឬដោយអចេតនា។ |
| **សមិទ្ធផលរំពឹងទុក** | ការជះឥទ្ធិពលរយៈពេលខ្លី និងមធ្យមនៃការអនុវត្តនូវលទ្ធផលរំពឹងទុកមួយ |
| **លទ្ធផលរំពឹងទុក** | ផលិតផល ឧបករណ៍ សម្ភារៈ និងសេវាទាំងឡាយដែលទទួលបានពីអន្តរាគមន៍អភិវឌ្ឍន៍មួយ ហើយវាក៏អាចរួមបញ្ចូលទាំងការផ្លាស់ប្ដូរនានាផ្ដើមពីអន្តរាគមន៍ដែលពាក់ព័ន្ធនឹងការសម្រេចនូវសមិទ្ធផលរំពឹងទុក។ |
| **សកម្មភាព** | ទង្វើដែលប្រកាន់យក ឬកិច្ចការដែលបានបំពេញដោយប្រើប្រាស់នូវធាតុចូលនានាដូចជា មូលនិធិ ជំនួយបច្ចេកទេស និងធនធានផ្សេងទៀតដែលបានកៀរគរ ដើម្បីបង្កើតចេញជាលទ្ធផលរំពឹងទុកជាក់លាក់នានា។ |
| **ធាតុចូល** | ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ធនធានសម្ភារៈ ឯកសារ របាយការណ៍នានា...ដែលបានប្រើប្រាស់សម្រាប់កិច្ចអន្តរាគមន៍ និងការរៀបចំផែនការ គម្រោង កម្មវិធីអភិវឌ្ឍន៍នានា។ |
| **សូចនាករ** | កត្តា ឬអញ្ញតជាបរិមាណ ឬជាគុណភាពដែលផ្ដល់ជាមធ្យោបាយមួយ មានលក្ខណៈសាមញ្ញ និងអាចជឿទុកចិត្តបានសម្រាប់វាស់វែងសមិទ្ធផល ឬឆ្លុះបញ្ចាំងពីការផ្លាស់ប្ដូរនានាកើតចេញពីអន្តរាគមន៍ណាមួយ ឬក៏ជួយក្នុងការវាយតម្លៃពីការបំពេញការងាររបស់តួអង្គអភិវឌ្ឍន៍ណាមួយ។ |

# សេចក្តីផ្តើម

នាពាក់កណ្តាលឆ្នាំ២០១៣ គ.ជ.អ.ប និងដៃគូអភិវឌ្ឍន៍នានារបស់ខ្លួនបានឯកភាពគ្នាក្នុងការពន្យារពេលនៃការអនុវត្ត ផអ៣ មួយឆ្នាំបន្ថែមទៀតរហូតដល់ដំណាច់ឆ្នាំ២០១៤។ ការពន្យារពេលនេះនឹងផ្តល់លទ្ធភាពក្នុងការអនុវត្តបញ្ចប់នូវលទ្ធផលរំពឹងទុកចម្បងៗមួយចំនួនដែលបានកំណត់នៅក្នុងឯកសារ ផអ៣ ព្រមទាំងផ្តល់នូវពេលវេលាបន្ថែមសម្រាប់ការរៀបចំផែនការអនុវត្តដំណាក់កាលទី២នៃកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ឯកសារពន្យារពេលនៃ ផអ៣ ដែលបានរៀបចំនៅក្នុងឆមាសទី២ឆ្នាំ២០១៣ និងបានអនុម័តដោយ គ.ជ.អ.ប នៅថ្ងៃទី៤ ខែធ្នូឆ្នាំ២០១៣ បានកំណត់នូវអាទិភាពជាគន្លឹះនានាសម្រាប់ឆ្នាំ២០១៤។ អាទិភាពទាំងនោះត្រូវបានឆ្លុះបញ្ចាំង និងកំណត់អំពីធនធានយ៉ាងច្បាស់លាស់នៅក្នុង ផ.ស.ថ ឆ្នាំ២០១៤នេះ។

នៅឆ្នាំ២០១៤ ផ.ស.ថ របស់ គ.ជ.អ.ប បានពិពណ៌នាអំពីអាទិភាពរំពឹងទុក លទ្ធផលរំពឹងទុក[1]សកម្មភាព និងថវិកាដែលបានគ្រោងសម្រាប់ឆ្នាំទី៤នៃការអនុវត្តកម្មវិធីជាតិ។ ឯកសារ ផ.ស.ថ នេះ ក៏បានបង្កើតនូវក្របខ័ណ្ឌសម្រាប់ការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ២០១៤ផងដែរ។ ក្នុងការសម្របសម្រួលការរៀបចំ ផ.ស.ថ គ.ជ.អ.ប បានពិចារណាលើឯកសារពន្យារពេល ផអ៣ បញ្ហាប្រឈមនៃការអនុវត្តនានាដែលបានជួបប្រទះក្នុងឆ្នាំ២០១៣ ព្រមទាំងរបកគំហើញ និងអនុសាសន៍នានានៃការវាយតម្លៃពាក់កណ្តាលអាណត្តិលើការអនុវត្ត ផអ៣ ដែលបានធ្វើឡើងក្នុងខែកញ្ញា ឆ្នាំ២០១២។ ក្នុងត្រីមាសទី៤ឆ្នាំ២០១៣ ការពិគ្រោះយោបល់ជាច្រើនជាមួយក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ភ្នាក់ងារអនុវត្តគម្រោងដាច់ដោយឡែក ព្រមទាំងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាត្រូវបានរៀបចំឡើង ដើម្បីព្រមព្រៀងគ្នាលើអាទិភាពជាយុទ្ធសាស្ត្រ និងលទ្ធផលរំពឹងទុក ការបញ្ជាក់នូវធនធានដែលអាចមាន និងការវិភាជន៍មូលនិធិ ព្រមទាំងការពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងបឋមនៃ ផ.ស.ថ ឆ្នាំ២០១៤។ សេចក្តីព្រាងលើកទី២នៃ ផ.ស.ថ ឆ្នាំ២០១៤ដែលបានកែសម្រួលក៏ត្រូវបានបង្ហាញសម្រាប់ការពិនិត្យ និងកែសម្រួលចុងក្រោយនៅក្នុងសិក្ខាសាលាជាតិស្តីពីការរៀបចំ ផ.ស.ថ របស់ គ.ជ.អ.ប នាថ្ងៃទី១៩-២០ ខែធ្នូ ឆ្នាំ២០១៣ដែលមានការចូលរួមពីមន្ត្រីជាន់ខ្ពស់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្តទាំង២៣ និងអភិបាលក្រុង ស្រុកមួយចំនួន ប្រធានមន្ទីរជំនាញពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនានាផងដែរ។

ចាប់ពីជំពូកទី១ដល់ជំពូកទី៦នៃឯកសារនេះរៀបរាប់អំពី ផ.ស.ថ របស់អនុកម្មវិធីនីមួយៗ។ បញ្ជីលម្អិតនៃសកម្មភាព ពេលវេលា និងថវិកាអាចស្វែងរកបានក្នុងគេហទំព័ររបស់ គ.ជ.អ.ប ៖ www.ncdd.gov.kh។

## ក. អាទិភាពសម្រាប់ឆ្នាំ២០១៤

នៅក្នុងសុន្ទរកថាបិទសិក្ខាសាលាជាតិស្តីពីការរៀបចំ ផ.ស.ថ ប្រចាំឆ្នាំ២០១៤របស់ គ.ជ.អ.ប **ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប** បានគូសបញ្ជាក់នូវអាទិភាពសំខាន់ៗចំនួន១៣ដែលបានកំណត់នៅក្នុងឯកសារពន្យារពេលនៃ ផអ៣។ អាទិភាពនីមួយៗមានភ្ជាប់ជាមួយនូវចំណុចដៅ និងគោលដៅជាក់លាក់មួយចំនួនដែលត្រូវសម្រេចឱ្យបាននៅក្នុងឆ្នាំ២០១៤។ អាទិភាពទាំងនោះមានដូចខាងក្រោម ៖

---

[1] ផែនការលម្អិតមានបង្ហាញនូវបញ្ជីលទ្ធផលរំពឹងទុក និងសកម្មភាពដែលត្រូវបានតាមដានត្រួតពិនិត្យនៅក្នុងប្រព័ន្ធទិន្នន័យផ.ស.ថ (NAD) ហើយត្រូវបានឯកភាពនៅក្នុងកិច្ចព្រមព្រៀងអនុវត្តរវាងលេខាធិការដ្ឋាន គ.ជ.អ.ប ជាមួយភ្នាក់ងារអនុវត្តនៅថ្នាក់ជាតិ និងនៅថ្នាក់រាជធានី ខេត្ត។

**១. ការពង្រឹងការគ្រប់គ្រងការអនុវត្តកម្មវិធី (លទ្ធផលរំពឹងទុកទី១.៨)**

**ត្រីមាសទី១ ៖** ពិនិត្យឡើងវិញនូវតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប ក្នុងការគ្រប់គ្រងការបំពេញការងារទំនាក់ទំនងនិងការសម្របសម្រួលជាមួយក្រសួង ស្ថាប័នលើបញ្ហាគោលនយោបាយជាយុទ្ធសាស្ត្រនានា ការពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប និងការធានាដល់ការអនុវត្តសេចក្តីសម្រេចនានា។

**ត្រីមាសទី៤ ៖** កិច្ចប្រជុំសម្របសម្រួលជាមួយស្ថាប័នអនុវត្ត ផអព ប្រចាំត្រីមាសត្រូវបានរៀបចំឡើងយ៉ាងទៀងទាត់នៅក្នុងឆ្នាំ២០១៤ ដោយមានរបៀបវារៈច្បាស់លាស់ មានការកត់ត្រាពីចំណុចដែលបានព្រមព្រៀងគ្នា មានកំណត់នូវចំណុចដៅ និងក្របខ័ណ្ឌពេលវេលាជាក់លាក់សម្រាប់អនុវត្តនូវចំណុចព្រមព្រៀងដែលបានឯកភាពគ្នាទាំងនោះ។

**ត្រីមាសទី៤ ៖** ក្នុងកិច្ចប្រជុំរបស់ គ.ជ.អ.ប យ៉ាងតិចចំនួន២ ត្រូវបានរាយការណ៍អំពីវឌ្ឍនភាពនៃគ្រប់ចំណុចដៅជាអាទិភាពទាំងអស់ ព្រមទាំងត្រូវបានពិភាក្សាដោយតម្លាភាព ហើយឯកភាពគ្នាលើវិធានការនានា ដើម្បីដោះស្រាយ និងសម្រេចបាននូវចំណុចដៅដែលមានការយឺតយ៉ាវនានា។

**២. ការអនុវត្តមូលនិធិក្រុង ស្រុក (លទ្ធផលរំពឹងទុកទី៤.៧)** ៖ នៅក្នុងឆ្នាំ២០១៤ មូលនិធិក្រុង ស្រុកត្រូវបានអនុវត្តយ៉ាងពេញលេញ។ ជាមួយគ្នានេះដែរ គម្រោងអភិវឌ្ឍក្រុង ស្រុកនឹងត្រូវបានធ្វើលទ្ធកម្ម ហើយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុត្រូវបានគ្រប់គ្រង ចាត់ចែង ស្របតាមអនុក្រឹត្យ និងប្រកាសនានា។

**ត្រីមាសទី១ ៖** ការបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ត្រូវបានរៀបចំសម្រាប់មន្ត្រីពាក់ព័ន្ធនានានៃរដ្ឋបាលក្រុង ស្រុកទាំងអស់។

**ត្រីមាសទី៣ ៖** ប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ត្រូវបានពិនិត្យ និងវាយតម្លៃ។

**ត្រីមាសទី៤ ៖** ការកែសម្រួលឡើងវិញតាមការចាំបាច់លើសេចក្តីណែនាំនានាត្រូវបានអនុវត្ត និងបានបណ្តុះបណ្តាលដល់មន្ត្រីពាក់ព័ន្ធនានានៃរដ្ឋបាលក្រុង ស្រុក។

**ត្រីមាសទី៤ ៖** ធនធានសមាសភាគអភិវឌ្ឍន៍នៃមូលនិធិក្រុង ស្រុកចំនួនប្រមាណ៨០% ត្រូវបានប្រើប្រាស់ដោយរដ្ឋបាលក្រុង ស្រុក។

**៣. ប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ (លទ្ធផលរំពឹងទុកទី៤.៣)** (ផ្អែកលើការសិក្សានៅឆ្នាំ២០១៣ស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ)

**ត្រីមាសទី២ ៖** ឯកសារគោលនយោបាយស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំបញ្ចប់ និងអនុម័ត។

**ត្រីមាសទី២ ៖** ចំណុចដៅនៃការអនុវត្តការងារសម្រាប់សូចនាករ "ប្រភពចំណូលផ្ទាល់/ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់" ទទួលបានការឯកភាពសម្រាប់រយៈពេលពីឆ្នាំ២០១៥-២០១៨ សម្រាប់ថ្នាក់រដ្ឋបាល និងប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ (ជាផ្នែកមួយនៃគោលនយោបាយ)។

**ត្រីមាសទី៣ ៖** ការអនុវត្តសាកល្បងលើការប្រមូល និងការគ្រប់គ្រងចំណូលផ្ទាល់នៅក្រុង ស្រុក ខណ្ឌមួយចំនួន។

**ត្រីមាសទី៤ ៖** ការអនុវត្តសាកល្បងនឹងត្រូវបានវាយតម្លៃ ដើម្បីជាមូលដ្ឋានសម្រាប់ការពិចារណាក្នុងការពង្រីកការអនុវត្តនៅឆ្នាំ២០១៥។

**៤. ការផ្ទេរមុខងារ (លទ្ធផលរំពឹងទុកទី១.២ និង ១.៣)**

**ត្រីមាសទី២ ៖** លិខិតបទដ្ឋានគតិយុត្តនានាស្តីពីមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងអនុម័ត។

**ត្រីមាសទី២ ៖** កិច្ចដំណើរការផ្ទេរមុខងារ និងលិខិតបទដ្ឋានគតិយុត្តនានាត្រូវបានពិនិត្យមើលឡើងវិញ និងត្រូវបានប្រើប្រាស់ជាធាតុចូល សម្រាប់ការរៀបចំផែនការអនុវត្តដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ។

**ត្រីមាសទី២ ៖** ចំណុចដៅនៃការបំពេញការងារតាមលក្ខណៈ SMART សម្រាប់កិច្ចដំណើរការផ្ទេរមុខងារសម្រាប់រយៈពេលពីឆ្នាំ២០១៥-២០១៨ ទទួលបានការឯកភាព។

**ត្រីមាសទី៣ ៖** ការសាកល្បងអំពីការផ្ទេរមុខងារក្នុងវិស័យអាទិភាពយ៉ាងតិចចំនួនពីរ (ដូចជា ការងារសុខភាព និងអនាម័យនៅជនបទ) ត្រូវបានអនុវត្ត និងវាយតម្លៃ។

**ត្រីមាសទី៤ ៖** ផែនការអនុវត្តនានាដែលជាលទ្ធផលនៃការសាកល្បងនៃការផ្ទេរមុខងារទាំងនេះ ត្រូវបានរៀបចំសម្រាប់ឆ្នាំ២០១៥។

**៥. គណនេយ្យភាពសង្គម (លទ្ធផលរំពឹងទុកទី១.៥)**

**ត្រីមាសទី១ ៖** ការអនុវត្តសាកល្បងអំពីកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ និងប័ណ្ណដាក់ពិន្ទុរបស់ប្រជាពលរដ្ឋត្រូវបានអនុវត្ត។

**ត្រីមាសទី២ ៖** សេចក្តីណែនាំ និងសៀវភៅណែនាំសម្រាប់ការអនុវត្តត្រូវបានរៀបចំបញ្ចប់ ។

**ត្រីមាសទី៤ ៖** គ្រប់ឃុំទាំងអស់ក្នុងស្រុកគោលដៅចំនួន២០ នឹងមានបិទផ្សាយព័ត៌មានជាសាធារណៈ និងមានការចូលរួមក្នុងកិច្ចដំណើរការនានានៃការតាមដានរបស់ប្រជាពលរដ្ឋ ព្រមទាំងបានរៀបចំផែនការសកម្មភាពនៃការងារគណនេយ្យភាពសង្គម ដើម្បីកែលម្អការផ្តល់សេវា។

**៦. លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ (លទ្ធផលរំពឹងទុកទី៣.១)**

**ត្រីមាសទី១ ៖** លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំបញ្ចប់ និងអនុម័ត។

**ត្រីមាសទី២ ៖** យន្តការគាំទ្រការអនុវត្តលក្ខន្តិកៈនេះត្រូវបានរៀបចំ ដោយរួមបញ្ចូលទាំងការផ្សព្វផ្សាយ និងការបណ្តុះបណ្តាល។

**ត្រីមាសទី៤ ៖** ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងផ្សព្វផ្សាយ។

**៧. យុទ្ធសាស្ត្រសម្រាប់ពង្រឹងតួនាទី និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងអាណត្តិទី២ (លទ្ធផលរំពឹងទុកទី១.១៣)**

**ត្រីមាសទី២ ៖** កិច្ចដំណើរការធ្វើសេចក្ដីសម្រេចចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអំពីវិធីសាស្ត្រនៃការផ្ដល់សេវាប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ និងវាយតម្លៃ ព្រមទាំងការណែនាំអំពីសេចក្ដីព្រាងនៃវិធានផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក ត្រូវបានរៀបចំបញ្ចប់។

**ត្រីមាសទី២ ៖** យុទ្ធសាស្ត្រស្ដីពីការពង្រឹងតួនាទី និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងអនុម័ត។

**ត្រីមាសទី៤ ៖** សកម្មភាពនានាដែលបានកំណត់ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រត្រូវបានអនុវត្ត។

**៨. ការរៀបចំប្រព័ន្ធកសាងផែនការ និងថវិកាសម្រាប់ប្រភេទផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (លទ្ធផលរំពឹងទុកទី៥.១)**

**ត្រីមាសទី១ ៖** សេចក្ដីព្រាងគោលនយោបាយស្ដីពីប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំបញ្ចប់ និងអនុម័តដោយ គ.ជ.អ.ប។

**ត្រីមាសទី២ ៖** ការសិក្សាមួយត្រូវបានរៀបចំ ដើម្បីធានាភាពប្រទាក់ក្រឡាគ្នាយ៉ាងល្អប្រសើររវាងកិច្ចដំណើរការនៃការកសាងផែនការ និងការរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការសិក្សានេះ ផ្ដោតទៅលើការពិនិត្យមើលឡើងវិញនូវសេចក្ដីណែនាំនានាស្ដីពីការកសាងផែនការ និងការរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមាននាពេលបច្ចុប្បន្ន និងការរៀបចំប្រតិទិននៃការរៀបចំថវិកា និងការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានភាពប្រទាក់ក្រឡាគ្នា ព្រមទាំងផ្ដោតលើការកែសម្រួលសេចក្ដីណែនាំនានាពាក់ព័ន្ធនឹងការកសាងផែនការ និងការរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ត្រីមាសទី៣ ៖** សេចក្ដីណែនាំទាំងអស់ដែលបានកែសម្រួលបញ្ចប់។

**ត្រីមាសទី៣ ៖** ការបណ្ដុះបណ្ដាលអំពីសេចក្ដីណែនាំដែលបានកែសម្រួលទាំងនេះត្រូវបានអនុវត្ត។

**៩. ការពង្រឹងប្រព័ន្ធត្រួតពិនិត្យមើលពីលើ ឬអធិការកិច្ច (លទ្ធផលរំពឹងទុកទី២.៧)**

**ត្រីមាសទី២ ៖** ប្រព័ន្ធ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការត្រួតពិនិត្យមើលពីលើ ឬអធិការកិច្ចលើការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ។

**ត្រីមាសទី៣ ៖** ប្រព័ន្ធនេះនឹងត្រូវបានអនុវត្តសាកល្បងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន។

**ត្រីមាសទី៤ ៖** ប្រព័ន្ធអធិការកិច្ចត្រូវបានវាយតម្លៃ ហើយការរៀបចំផែនការអនុវត្តសម្រាប់ឆ្នាំ២០១៥ត្រូវបានរៀបចំបញ្ចប់។

**១០. យុទ្ធសាស្ត្រសម្រាប់ការពង្រឹងសមត្ថភាពផ្នែករដ្ឋបាលរបស់ក្រុង ស្រុក (លទ្ធផលរំពឹងទុកទី១.៤, ១.៧ និង ២.៤)**

**ត្រីមាសទី១ ៖** ថវិកាកម្មវិធីនឹងត្រូវបានផ្តល់ឱ្យទៅរដ្ឋបាលក្រុង ស្រុក ដើម្បីគាំទ្រដល់ការជ្រើសរើសមន្រ្តីកិច្ចសន្យាតាមតម្រូវការជាក់ស្តែង និងដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពយុទ្ធសាស្រ្តជាក់លាក់នានាដែលពុំអាចរ៉ាប់រងដោយមូលនិធិរបស់រដ្ឋបាលក្រុង ស្រុក។

**ត្រីមាសទី២ ៖** សៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការរបស់រដ្ឋបាលក្រុង ស្រុក ត្រូវបានរៀបចំបញ្ចប់ព្រមទាំងត្រូវបានផ្សព្វផ្សាយ តាមរយៈការរៀបចំកម្មវិធីបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុកទាំងអស់។

**ត្រីមាសទី២ ៖** យុទ្ធសាស្រ្តអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានពិនិត្យ និងកែសម្រួលឡើងវិញ។ កិច្ចការនេះក៏ជាផ្នែកមួយនៃកិច្ចដំណើរការរៀបចំតាក់តែង ផអ៣ ដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ។

**១១. សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ (លទ្ធផលរំពឹងទុកទី៦.១ និង ៦.២)៖** ក្នុងឆ្នាំ២០១៣ សមាគមក្រុមប្រឹក្សារាជធានី ខេត្តត្រូវបានបង្កើតជាផ្លូវការរួចហើយ។ ជាមួយគ្នានេះដែរ សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក៏ត្រូវបានបង្កើតនៅតាមរាជធានី ខេត្តចំនួន១១។

**ត្រីមាសទី១ ៖** សមាគមក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់ដែលបានបង្កើតរួចហើយនៅតាមខេត្តទាំង១១នេះត្រូវបានបញ្ចូលគ្នា ដើម្បីបង្កើតជាសម្ព័ន្ធភាពជាតិនៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

**ត្រីមាសទី២ ៖** សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នៅតាមខេត្តចំនួន១៣ផ្សេងទៀតត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ និងបានបញ្ចូលទៅក្នុងសម្ព័ន្ធភាពជាតិដូចមានរៀបរាប់ខាងលើ។

**ត្រីមាសទី២ ៖** រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានសម្រាប់គាំទ្រសមាគមទាំងពីរ ត្រូវបានពិនិត្យ និងកែសម្រួលឡើងវិញដោយមានការកំណត់អំពីលក្ខខណ្ឌការងារយ៉ាងជាក់លាក់។

**១២. ការបញ្ជ្រាបយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្រ្តី (លទ្ធផលរំពឹងទុកទី១.១៤)**

**ត្រីមាសទី២ ៖** ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មយេនឌ័រ ដែលបានបញ្ចប់នៅខែមករាឆ្នាំ២០១៤ ផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០១៤ត្រូវបានពិនិត្យកែសម្រួល ដើម្បីបញ្ចូលនូវសកម្មភាពជាក់លាក់ដែលត្រូវអនុវត្តដោយស្ថាប័នអនុវត្ត ផអ៣ នីមួយៗរួមបញ្ចូលទាំងសេចក្តីណែនាំពាក់ព័ន្ធបញ្ហាយេនឌ័រសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

**ត្រីមាសទី២ ៖** លទ្ធផលនៃការធ្វើសវនកម្មយេនឌ័រត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំតាក់តែង ផអ៣ ដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ រួមទាំងការកែសម្រួល ឬការរៀបចំឡើងវិញនូវយុទ្ធសាស្រ្តស្តីពីការបញ្ជ្រាបយេនឌ័រផងដែរ។

**១៣. ការរៀបចំតាក់តែង ផអ៣ ដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ (លទ្ធផលរំពឹងទុកទី១.៧)**

**ត្រីមាសទី១ ៖** នៅក្នុងខែមករា ឆ្នាំ២០១៤ លក្ខខណ្ឌការងារសម្រាប់ការរៀបចំតាក់តែង ផអ៣ ដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិត្រូវបានរៀបចំ និងឯកភាពពីដៃគូអភិវឌ្ឍន៍នានា។ លក្ខខណ្ឌ

ការងារនេះរួមបញ្ចូលនូវដំណើរការ និងវិសាលភាពនៃការតាក់តែង តម្រូវការទីប្រឹក្សាដែលត្រូវជ្រើសរើស ការសិក្សានានាត្រូវបានរៀបចំ ហើយការកំណត់ពីការពិនិត្យមើលឡើងវិញ និងការវាយតម្លៃនានាដែលបានអនុវត្តកន្លងសម្រាប់ប្រើប្រាស់ក្នុងការរៀបចំតាក់តែង និងការរៀបចំក្របខ័ណ្ឌពេលវេលាសម្រាប់ការរៀបចំឯកសារនេះ។

**ត្រីមាសទី២ ៖** ការរៀបចំសេចក្ដីព្រាងលើកទី១នៃ ផអ៣ ដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិត្រូវបានរៀបចំបញ្ចប់ (ក្នុងខែឧសភា ឆ្នាំ២០១៤)។

**ត្រីមាសទី៣ ៖** ការសិក្សាវាយតម្លៃរួមគ្នា (នៅក្នុងខែកក្កដា ឆ្នាំ២០១៤)។

**ត្រីមាសទី៣ ៖** សេចក្ដីព្រាងចុងក្រោយត្រូវបានរៀបចំបញ្ចប់ (ក្នុងខែកញ្ញាឆ្នាំ២០១៤)។

## ២. ថវិកាសម្រាប់ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤

### ២.១. គម្រោងចំណាយ

គម្រោងចំណាយសម្រាប់ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤ ត្រូវបានផ្ដល់ហិរញ្ញប្បទានតាមរយៈមូលនិធិកញ្ចប់រួមមានចំនួន១៣.៥៨៦.៦២៩ដុល្លារអាមេរិក។ ថវិកានេះមានការកើនឡើង២៨%ធៀបនឹងថវិកាឆ្នាំ២០១៣។ ប្រសិនបើគិតបញ្ចូលទាំងថវិកាសម្រាប់ការពន្យារពេលនៃ ផអ៣ ថវិកាសរុបសម្រាប់ការអនុវត្តកម្មវិធីក្នុងរយៈពេល៤ឆ្នាំនេះមានចំនួនប្រមាណ ៥៩,២១លានដុល្លារអាមេរិក ធៀបនឹងថវិកាគ្រោងចំនួន៦៨,៨៤លានដុល្លារដូចដែលបានប៉ាន់ស្មាននៅក្នុងឯកសារ ផអ៣។ នេះមានន័យថា ថវិកាចំណាយសរុបមានចំនួន១៤%តិចជាងការរំពឹងទុក។ ជារួម ទោះបីជាថវិកាប្រតិបត្តិការត្រូវបានកាត់បន្ថយ ហើយរយៈពេលអនុវត្តវែងជាងការគ្រោងក៏ដោយ ក៏ធនធាននានាដែលទទួលបានចាត់ទុកថាមានចំនួនគ្រប់គ្រាន់ ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនានាដែលបានកំណត់នៅក្នុង ផអ៣។




**ប្រអប់ទី១៖ និន្នាការនៃមូលនិធិកញ្ចប់រួម**

ដោយមិនគិតបញ្ចូលពីសកម្មភាពនៃការរួមចំណែកមិនមែនជាថវិកា គម្រោងចំណាយក្នុង ផអ៣ ត្រូវបានបែងចែកជាបីប្រភេទគឺ (១)មូលនិធិកញ្ចប់រួមសម្រាប់សកម្មភាពកំណែទម្រង់ចម្បងៗ (២)គម្រោងពាក់ព័ន្ធ និងមូលនិធិមានកំណត់គោលដៅប្រើប្រាស់ និង (៣) ការផ្ទេរសារពើពន្ធ។ ទិដ្ឋភាពរួមនៃគម្រោងចំណាយទាំងនេះតាមអនុកម្មវិធីនីមួយៗមានបង្ហាញក្នុងតារាងខាងក្រោម។

**តារាងទី១ ៖ ទិដ្ឋភាពរួមនៃគម្រោងចំណាយថវិកាឆ្នាំ២០១៩**

| អនុកម្មវិធី | ក. កញ្ចប់រួម | %កញ្ចប់រួម | ខ. មូលនិធិមានកំណត់គោលដៅ | គ. ការផ្ទេរសារពើពន្ធ | សរុប (ក+ខ+គ) | %សរុប |
|---|---|---|---|---|---|---|
| អនុកម្មវិធីទី១ | $4,835,299 | 35.59% | $17,862,525 | $0 | **$22,697,824** | 8.22% |
| អនុកម្មវិធីទី២ | $575,494 | 4.24% | $4,740,820 | $0 | **$5,316,314** | 1.93% |
| អនុកម្មវិធីទី៣ | $356,820 | 2.63% | $0 | $0 | **$356,820** | 0.13% |
| អនុកម្មវិធីទី៤ | $175,357 | 1.29% | $5,004,044 | $233,863,704 | **$239,043,105** | 86.59% |
| – សកម្មភាពកំណែទម្រង់ | $175,357 | | $1,004,044 | $0 | **$1,179,401** | 0.43% |
| – ការផ្ទេរសារពើពន្ធ | $0 | | $4,000,000 | $233,863,704 | **$237,863,704** | 86.16% |
| អនុកម្មវិធីទី៥ | $45,490 | 0.33% | $139,000 | $0 | **$184,490** | 0.07% |
| អនុកម្មវិធី ទី៦ | $120,520 | 0.89% | $389,682 | $0 | **$510,202** | 0.18% |
| រដ្ឋបាលថ្នាក់ក្រោមជាតិ (ចំណាយរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) | $7,477,649 | 55.04% | $491,328 | $0 | **$7,968,978** | 2.89% |
| **សរុប** | **$13,586,629** | **100.00%** | **$28,627,399** | **$233,863,704** | **$276,077,733** | **100.00%** |
| **ភាគរយ (%)** | 4.92% | | 10.37% | 84.71% | 100.00% | |

**សម្គាល់** ៖ តួលេខខាងលើនេះមិនបូកបញ្ចូលការចូលរួមចំណែកមិនមែនជាថវិកាទេ។ ការផ្ទេរសារពើពន្ធត្រូវបានផ្តល់ហិរញ្ញប្បទានដោយរាជរដ្ឋាភិបាលកម្ពុជា និង Sida ។ មូលនិធិដែលមានកំណត់គោលដៅប្រើប្រាស់របស់អនុកម្មវិធីទី១រួមបញ្ចូលការរួមចំណែកពីរដ្ឋាភិបាលចំនួន១២៥.០០០ដុល្លារដើម្បីគាំទ្រដល់លេខាធិការដ្ឋាន គ.ជ.អ.ប ។

ដូចបានបង្ហាញខាងលើ គម្រោងចំណាយមានកំណត់គោលដៅ មានចំនួនប្រហែល២,១ដងធៀបនឹងគម្រោងចំណាយថវិកាកញ្ចប់រួម ។ សកម្មភាពដែលត្រូវប្រើប្រាស់ថវិកាកញ្ចប់រួមប្រហែលពាក់កណ្តាល (៥៥%) នឹងត្រូវបានអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ទិន្នន័យសម្រាប់ការផ្ទេរសារពើពន្ធមានបង្ហាញនៅក្នុងតារាងទី២ ។

**តារាងទី២ ៖ សារពើពន្ធដែលគ្រោងផ្ទេរសម្រាប់ឆ្នាំ២០១៩**

| មូលនិធិ | ស៊ីដា | រាជរដ្ឋាភិបាល | សរុប |
|---|---|---|---|
| មូលនិធិឃុំ សង្កាត់ | $0 | $58,584,198 | $58,584,198 |
| មូលនិធិក្រុង ស្រុក | $4,000,000 | $17,047,901 | $21,047,901 |
| ថវិការាជធានី ខេត្ត | $0 | $158,231,605 | $158,231,605 |
| **សរុប** | **$4,000,000** | **$233,863,704** | **$237,863,704** |

### ខ.២ ប្រភពមូលនិធិ

ថវិកាសរុបពីរាជរដ្ឋាភិបាលកម្ពុជាមានចំនួន២៣៣.៩៨៨.៧០៤ដុល្លារអាមេរិកក្នុងនោះរួមមាន ការផ្ទេរមូលនិធិប្រមាណ២៣៣.៨៦៣.៧០៤ដុល្លារទៅឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត (សូមមើលតារាងទី២) រួមទាំងថវិកាចំនួន១២៥.០០០ដុល្លារសម្រាប់គាំទ្រដល់លេខាធិការដ្ឋាន គ.ជ.អ.ប[2] ។ ជារួម ថវិការបស់រាជរដ្ឋាភិបាលមានចំនួន៨២.៦% នៃការផ្តល់មូលនិធិសរុប ។

[2] ចំនួននេះត្រូវបានគិតថាជាមូលនិធិមានគោលដៅក្នុងតារាងទី១។

ចំពោះប្រភពមូលនិធិពីដៃគូអភិវឌ្ឍន៍រួមមាន ការចំណាយឆន្ទានុសិទ្ធិនៃថវិកាកញ្ចប់រួម មូលនិធិមានកំណត់គោលដៅប្រើប្រាស់ ការរួមចំណែកមិនមែនថវិកា និងការរួមចំណែកចំពោះយន្តការនៃការផ្ទេរសារពើពន្ធ។ មូលនិធិគាំទ្រតាមប្រភពនីមួយៗត្រូវបានលម្អិតដូចខាងក្រោម ៖

**តារាងទី៣ ៖ ប្រភពមូលនិធិ ផ.ស.ថ ឆ្នាំ២០១៤**

| ប្រភពមូលនិធិ | ក.អាចរៀបចំជាកម្មវិធី | ខ. មានគោលដៅប្រើប្រាស់ | គ. សរុប | ការចូលរួមមិនមែនថវិកា | ឃ.ផ្ទេរទៅថ្នាក់ក្រោមជាតិ | សរុប (គ+ឃ) | ភាគរយ |
|---|---|---|---|---|---|---|---|
| **១. រាជរដ្ឋាភិបាល** | **$0** | **$125,000** | **$125,000** | **$0** | **$233,863,704** | **$233,988,704** | **82.69%** |
| **២. ដៃគូអភិវឌ្ឍន៍** | | | | | | | |
| Sweden/Sida | $4,500,000 | | $4,500,000 | | $4,000,000 | $8,500,000 | 3.00% |
| EU | $7,000,000 | | $7,000,000 | | | $7,000,000 | 2.47% |
| Swiss/ SDC | $2,600,000 | | $2,600,000 | | | $2,600,000 | 0.92% |
| ADB/PPTA (1) | | | $0 | $850,000 | | $850,000 | 0.30% |
| ADB/DPSFM (1) | | $5,850,000 | $5,850,000 | | | $5,850,000 | 2.07% |
| ADB/TS-PRSDP | | $895,142 | $895,142 | | $14,029,062 | $14,924,204 | 5.27% |
| EU-SPACE | | | $0 | $1,600,000 | | $1,600,000 | 0.57% |
| AUSAID-UNCDF | | $500,000 | $500,000 | | | $500,000 | 0.18% |
| JICA/ PILAC2 | | | $0 | $100,000 | | $100,000 | 0.04% |
| UNDP/SNC Scale-up | | $800,000 | $800,000 | | | $800,000 | 0.28% |
| UNDP/ACES | | $1,234,349 | $1,234,349 | | | $1,234,349 | 0.44% |
| UNICEF/Seth Koma | | $1,485,415 | $1,485,415 | $902,744 | $481,284 | $2,869,443 | 1.01% |
| UNCDF/LGCC2 | | $73,120 | $73,120 | | $204,800 | $277,920 | 0.10% |
| UN/Women | | $34,000 | $34,000 | | | $34,000 | 0.01% |
| UNFPA | | $300,000 | $300,000 | | | $300,000 | 0.11% |
| WB-OWSO | | $498,227 | $498,227 | | | $498,227 | 0.18% |
| WB-LASED | | $1,056,402 | $1,056,402 | | | $1,056,402 | 0.37% |
| **សរុបរង** | $14,100,000 | $12,726,654 | $26,826,654 | $3,452,744 | $18,715,146 | $48,994,544 | 17.31% |
| **ភាគរយ** | 29% | 26% | 55% | 7% | 38% | 100% | |
| **៣. សរុប (១+២)** | **$14,100,000** | **$12,851,654** | **$26,951,654** | **$3,452,744** | **$252,578,850** | **$282,983,248** | **100%** |
| **ភាគរយ** | 5% | 5% | 10% | 1% | 89% | 100% | |

**សម្គាល់** ÷ (1) មូលនិធិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានគ្រប់គ្រងដោយគណនីដោយឡែកជាមួយអនុកម្មវិធីទី១ ទី២ និងអនុកម្មវិធីទី៤។

### ខ.៣. សមតុល្យ

ចំពោះមូលនិធិកញ្ចប់រួម គម្រោងថវិកាចំណាយសរុបមានចំនួន១៣.៥៨៦.៦២៩ដុល្លារ ធៀបនឹងធនធានសរុបនៃមូលនិធិកញ្ចប់រួមដែលមានចំនួន១៤.១០០.០០០ដុល្លារ។ ដូច្នេះ សមតុល្យថវិកាដែលនៅសល់មានចំនួន៥១៣.៣៧១ដុល្លារដែលអាចប្រើប្រាស់សម្រាប់សកម្មភាព និងតម្រូវការផ្សេងទៀតដែលមិនបានគ្រោងទុកក្នុងឆ្នាំ។

## គ. ជំនួយបច្ចេកទេស

ក្នុងឆ្នាំ២០១៤នឹងមានការកាត់បន្ថយការគាំទ្រជំនួយបច្ចេកទេស ជាពិសេសការកាត់បន្ថយនូវចំនួនទីប្រឹក្សាជាតិ និងអន្តរជាតិទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ប៉ុន្តែដើម្បីផ្តោតការយកចិត្តទុកដាក់តែខ្លាំងលើរដ្ឋបាលថ្នាក់ក្រុង ស្រុក ដូចនេះចំនួនមន្ត្រីកិច្ចសន្យានៅថ្នាក់ក្រុង ស្រុកនឹងមានការកើនឡើង។ ចំនួនបុគ្គលិកសម្រាប់ឆ្នាំ២០១៤នៅតែមានចំនួនច្រើន អាស្រ័យហេតុនេះការបែងចែកតួនាទី និងការទទួលខុសត្រូវរវាងទីប្រឹក្សា និងមន្ត្រីកិច្ចសន្យា គឺជាកិច្ចការដ៏ចាំ

បាច់។ ទីប្រឹក្សាត្រូវបានជ្រើសរើស និងផ្តល់កិច្ចសន្យាបម្រើការងារដោយលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងកម្រិតប្រាក់បៀវត្សមួយដែលមានលក្ខណៈប្រកួតប្រជែងជាមួយអង្គការអន្តរជាតិនានាក្នុងគោលបំណង ១) អភិវឌ្ឍសមត្ថភាព និង ២)បំពេញកិច្ចការនានារបស់កម្មវិធីដែលផ្តល់ហិរញ្ញប្បទានពីខាងក្រៅ។ បុគ្គលិកកិច្ចសន្យាត្រូវបានជ្រើសរើសជាបឋមដោយថ្នាក់ក្រោមជាតិ ដោយមានកម្រិតប្រាក់បៀវត្សប្រហាក់ប្រហែលនឹងកម្រិតប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិលដើម្បីជួយពង្រឹងសមត្ថភាពដែលនៅខ្វះចន្លោះក្នុងការបំពេញការងារចាំបាច់នានា។ ដោយសារមានការបង្កកការជ្រើសរើសមន្ត្រីរាជការ និងភាពខ្វះខាតនៃចំនួនបុគ្គលិករបស់ក្រុង ស្រុក អាស្រ័យហេតុនេះ ការអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើសបុគ្គលិកកិច្ចសន្យា (ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាជាមួយនឹងការរៀបចំក្នុងវិស័យដទៃ) គឺជាជម្រើសតែមួយគត់សម្រាប់លេខាធិការដ្ឋាន គ.ជ.អ.ប។ យើងមានការសង្ឃឹមថា បុគ្គលិកកិច្ចសន្យាទាំងនេះមួយចំនួនធំនឹងត្រូវបានជ្រើសរើសជាមន្ត្រីរាជការស៊ីវិលនៅពេលដែលមានការអនុញ្ញាតឱ្យមានការជ្រើសរើសមន្ត្រីក្របខ័ណ្ឌ។ នៅក្នុងឆ្នាំ២០១៤នេះ ទីប្រឹក្សាអន្តរជាតិនឹងមានចំនួនតែ២,៥រូបប៉ុណ្ណោះ ហើយទីប្រឹក្សាជាតិមានចំនួន៩៤រូបនៅថ្នាក់រាជធានី ខេត្ត ដែលនេះគឺជាចំនួនទាបបំផុតនៃការគាំទ្រទីប្រឹក្សាបច្ចេកទេសក្នុងរយៈពេល១៥ឆ្នាំចុងក្រោយនេះសម្រាប់កម្មវិធីមួយដែលមានវិសាលភាពកាន់តែធំ និងមានភាពស្មុគស្មាញកាន់តែខ្លាំងជាងមុន។ ក្រៅពីនេះ នៅមានទីប្រឹក្សាចំនួន០១រូបសម្រាប់ក្រុង ស្រុកនីមួយៗ (ក្រុង ស្រុកសរុបមានចំនួន១៨៥) ចំណែកជំនួយបច្ចេកទេសផ្សេងទៀត គឺជាបុគ្គលិកកិច្ចសន្យា។ ជារួម មានបុគ្គលិកចំនួន៩៨៨រូបនឹងត្រូវបានជ្រើសរើស និងតែងតាំងឱ្យបម្រើការងារនៅក្នុងកម្មវិធីដែលត្រូវចំណាយថវិកាប្រមាណជា៥,៩លានដុល្លារអាមេរិក។ ក្នុងអំឡុងពេលនៃការរៀបចំតាក់តែងផែនការអនុវត្តដំណាក់កាលបន្ទាប់ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងពិនិត្យឡើងវិញនូវបញ្ហាដែលពាក់ព័ន្ធនឹងចំនួនទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យា ដោយពិចារណាជាបឋមលើបន្ទុកការងារពាក់ព័ន្ធនានាដែលតម្រូវដោយកម្មវិធីជាតិដែលមានសមាសភាគជាច្រើន និងការគាំទ្រដល់គម្រោងដាច់ដោយឡែកជាច្រើនទៀតរបស់ដៃគូអភិវឌ្ឍន៍នានាដែលកំពុងអនុវត្តក្នុងក្របខ័ណ្ឌគាំទ្រ និងសម្របសម្រួលរបស់ គ.ជ.អ.ប។ ទិន្នន័យស្តីពីបុគ្គលិកមានសង្ខេបដូចក្នុងតារាងខាងក្រោម ៖

**តារាងទី៤ ៖ ជំនួយបច្ចេកទេស និងបុគ្គលិកកិច្ចសន្យា**

| ប្រភេទ | ចំនួនបុគ្គលិក | | | | | | ប្រាក់បៀវត្ស | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទីប្រឹក្សាអន្តរជាតិ | ទីប្រឹក្សាជាតិ | បុគ្គលិកកិច្ចសន្យា | បុគ្គលិកគាំទ្រ | សរុប | ភាគរយ | ទីប្រឹក្សាអន្តរជាតិ | ទីប្រឹក្សាជាតិ | បុគ្គលិកកិច្ចសន្យា | បុគ្គលិកគាំទ្រ | សរុប | ភាគរយ |
| អនុកម្មវិធីទី១ | 3.00 | 17.00 | 43.00 | 27.00 | 90.00 | 9.02% | $483,363 | $455,040 | $360,840 | $79,920 | $1,379,163 | 23.39% |
| អនុកម្មវិធីទី២ | 0.00 | 7.00 | 5.00 | 5.00 | 17.00 | 1.70% | $0 | $155,834 | $37,440 | $14,400 | $207,674 | 3.52% |
| អនុកម្មវិធីទី៣ | 0.00 | 1.00 | 0.00 | 1.00 | 2.00 | 0.20% | $0 | $27,060 | $0 | $3,360 | $30,420 | 0.52% |
| អនុកម្មវិធីទី៤ | 0.00 | 1.00 | 1.00 | 3.00 | 5.00 | 0.50% | $0 | $27,060 | $4,140 | $10,080 | $41,280 | 0.70% |
| អនុកម្មវិធីទី៥ | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00% | $0 | $0 | $0 | $0 | $0 | 0.00% |
| អនុកម្មវិធីទី៦ | 0.00 | 1.00 | 4.00 | 1.00 | 6.00 | 0.60% | $0 | $18,960 | $36,000 | $3,360 | $58,320 | 0.99% |
| រាជធានី ខេត្ត | 0.00 | 94.00 | 56.00 | 118.00 | 268.00 | 26.85% | $0 | $1,713,120 | $355,200 | $254,880 | $2,323,200 | 39.40% |
| ក្រុង ស្រុក ខណ្ឌ | 0.00 | 185.00 | 425.00 | 0.00 | 610.00 | 61.12% | $0 | $865,800 | $990,000 | $0 | $1,855,800 | 31.48% |
| **សរុប** | **3.00** | **306.00** | **534.00** | **155.00** | **998.00** | **100.00%** | **$483,363** | **$3,262,874** | **$1,783,620** | **$366,000** | **$5,895,857** | **100.00%** |
| **ភាគរយ** | **0.30%** | **30.66%** | **53.51%** | **15.53%** | **100%** | | **8.20%** | **55.34%** | **30.25%** | **6.21%** | **100%** | |

**សម្គាល់** ÷ ទីប្រឹក្សាអន្តរជាតិមានរយៈពេល៣០ខែ និងបុគ្គលិកការិយាល័យច្រកចេញចូលតែមួយខ្លះនឹងបំពេញការងារក្នុងរយៈពេល១០ខែ។

# ជំពូកទី១ ÷ ការអភិវឌ្ឍគោលនយោបាយ និងការសម្របសម្រួលកម្មវិធី
# (អនុកម្មវិធីទី១)

## ១.១. សេចក្ដីផ្ដើម

អនុកម្មវិធីទី១ដែលទទួលខុសត្រូវអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប ផ្ដោតជាសំខាន់ទៅលើការពង្រឹងការសម្របសម្រួលឱ្យមានការព្រមព្រៀងគ្នាក្នុងចំណោមក្រសួង ស្ថាប័នរាជរដ្ឋាភិបាលទាំងមូលទៅលើគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងការអភិវឌ្ឍគោលនយោបាយវិមជ្ឈការសារពើពន្ធ និងវិមជ្ឈការតាមវិស័យពាក់ព័ន្ធនានា សម្រាប់ការអនុវត្តច្បាប់រៀបចំអង្គការ និងជំរុញកិច្ចអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ជាមួយគ្នានេះដែរ អនុកម្មវិធីទី១ក៏ផ្ដោតលើការជំរុញការអនុវត្តកំណែទម្រង់តាមវិស័យនានា (តាមរយៈការផ្ទេរមុខងារ) ការរៀបចំប្រព័ន្ធពិគ្រោះយោបល់នានារបស់ក្រុមប្រឹក្សា ការផ្ដល់សេវាសម្របសម្រួល និងប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សា ការត្រួតពិនិត្យតាមដាន ការវាយតម្លៃ និងការបញ្ជ្រាបយេនឌ័រ។ សមិទ្ធផលរំពឹងទុកនានារបស់អនុកម្មវិធីទី១មានដូចខាងក្រោម៖

### ប្រអប់ទី២៖ សមិទ្ធផលរំពឹងទុកនៃផអ៣របស់អនុកម្មវិធីទី១

**សមិទ្ធផលរំពឹងទុក ÷**

- ក្រុមប្រឹក្សាកាន់តែមានការយល់ដឹង និងចំណេះដឹងប្រសើរជាងមុន [1.1, 1.4, 1.12, 1.13]។
- ក្រុមប្រឹក្សាអនុវត្តការងាររបស់ខ្លួន ព្រមទាំងទទួលបាននូវព័ត៌មាន និងធ្វើការសម្រេចចិត្តកាន់តែប្រសើរឡើង [1.1, 1.5, 1.9, 1.12, 1.13]។
- តម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋ (រួមទាំងក្រុមជនងាយរងគ្រោះ) ត្រូវបានឆ្លុះបញ្ចាំងកាន់តែច្បាស់ក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ការរៀបចំផែនការ ថវិកា និងការអនុវត្តរបស់ក្រុមប្រឹក្សា [1.1, 1.5]។
- ស្ត្រីត្រូវបានផ្ដល់សិទ្ធិអំណាច សក្ដានុពលរបស់ស្ត្រីត្រូវបានទទួលស្គាល់ពិតប្រាកដ និងក្រុមជនងាយរងគ្រោះទទួលបានការគាំទ្រ លើកស្ទួយ និងការពារកាន់តែប្រសើរឡើងពីរដ្ឋបាលថ្នាក់ក្រោមជាតិ (វិសមភាពត្រូវបានកាត់បន្ថយ) [1.1, 1.5, 1.14]។
- រដ្ឋបាលថ្នាក់ក្រោមជាតិមានការគ្រប់គ្រងកាន់តែល្អប្រសើរ (កាន់តែមានតម្លាភាព កាន់តែមានចូលរួមទូលំទូលាយ មានគណនេយ្យភាពកាន់តែច្រើន និងអំពើពុករលួយកាន់តែថយចុះ) ហើយប្រតិបត្តិការរបស់ក្រុមប្រឹក្សាកាន់តែមានភាពល្អប្រសើរឡើង [1.4, 1.5, 1.9, 1.14]។
- រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានគំនិតច្នៃប្រឌិតថ្មី និងមានស្វ័យភាពកាន់តែច្រើន [1.1, 1.3]។
- មុខងារផ្ដល់សេវាដែលបានរៀបចំ ឬបានផ្ទេរជូនរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តកាន់តែមានប្រសិទ្ធភាព និងភាពស័ក្ដិសិទ្ធិជាងការអនុវត្តដោយថ្នាក់ថ្នាក់ជាតិ [1.1, 1.2]។
- រដ្ឋបាលថ្នាក់ក្រោមជាតិ បានកែលម្អការផ្ដល់សេវានានារបស់ខ្លួន (ដោយសារមានការគ្រប់គ្រង និងដឹកនាំបានល្អ) [1.15, 1.16]។

**សម្គាល់ ៖** លទ្ធផលរំពឹងទុកនានាដែលរួមចំណែកដោយផ្ទាល់ដល់សមិទ្ធផលនីមួយៗដូចមានបញ្ជាក់ក្នុងវង់ក្រចក។ លទ្ធផលរំពឹងទុកមួយអាចរួមចំណែកដល់សមិទ្ធផលច្រើន។ លទ្ធផលរំពឹងទុកទាំងអស់នឹងរួមចំណែកដល់ការពង្រឹងសមត្ថភាពរបស់លេខាធិការដ្ឋាន គ.ជ.អ.ប។ សមិទ្ធផលទាំងអស់គ្របដណ្ដប់ក្នុងរយៈពេលផអ៣ទាំងមូល។

## ១.២. លទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី១

**លទ្ធផលរំពឹងទុកទី១.១៖ ការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តចំនួន១០របស់អនុកម្មវិធីនានាត្រូវបានសម្របសម្រួល និងគាំទ្រដោយលេខាធិការដ្ឋាន គ.ជ.អ.ប ព្រមទាំងត្រូវបានពិនិត្យឡើងវិញអំពីផលប៉ះពាល់ចំពោះយេនឌ័រ។** ការផ្តល់ការសម្របសម្រួល និងគាំទ្រនេះ ដើម្បីធានាឱ្យមានសង្គតិភាពនៃគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តទាំងនោះជាមួយនឹងច្បាប់រៀបចំអង្គការ និងគោលនយោបាយវិមជ្ឈការ និងសហវិមជ្ឈការ[3]។ ក្នុងការរៀបចំផែនការអនុវត្តដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ កិច្ចដំណើរការរៀបចំគោលនយោបាយ (រួមបញ្ចូលទាំងកម្រិតនៃគោលនយោបាយដែលគួរត្រូវជំរុញឱ្យមានការបញ្ជ្រាបយេនឌ័រប្រកបដោយប្រសិទ្ធភាព) ត្រូវបានពិនិត្យឡើងវិញ និងកែសម្រួលយ៉ាងយកចិត្តទុកដាក់។

**លទ្ធផលរំពឹងទុកទី១.២៖ ការផ្ទេរមុខងារនានាក្នុងលក្ខណៈសាកល្បង ឬលក្ខណៈអចិន្ត្រៃយ៍។** រហូតដល់ចុងឆ្នាំ២០១៤ របាយការណ៍ស្តីពីការវិភាគមុខងារ (និងការវិភាគផ្សេងទៀត) និងរបាយការណ៍ស្តីពីការពិនិត្យឡើងវិញនូវមុខងារនឹងត្រូវបានរៀបចំបញ្ចប់ដោយក្រសួងពាក់ព័ន្ធចំនួន៥។ នៅចុងឆ្នាំ២០១៤ ក្រសួងទាំង៥នេះនឹងធ្វើការសម្រេចយ៉ាងច្បាស់លាស់អំពីមុខងារ និងធនធានដែលត្រូវផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ យ៉ាងហោចណាស់ក៏មានគម្រោងសាកល្បងផ្ទេរមុខងារចំនួន២ (គឺមុខងារពាក់ព័ន្ធនឹងសុខភាព និងអនាម័យជនបទ) រំពឹងថានឹងត្រូវបានរៀបចំតាក់តែង និងចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ២០១៤។ នៅក្នុងការរៀបចំផែនការអនុវត្តដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ និងផ្អែកតាមធាតុចូលរបស់ EU-SPACE កិច្ចដំណើរការផ្ទេរមុខងារនឹងត្រូវបានពិនិត្យ និងកែសម្រួលឡើងវិញដោយយកចិត្តទុកដាក់។

**លទ្ធផលរំពឹងទុកទី១.៣៖ ការកំណត់នូវមុខងារជាជម្រើស (មុខងារជាអាណត្តិទូទៅ) និងការអនុវត្តសាកល្បងដោយប្រើប្រាស់មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ និងមូលនិធិមកពីប្រភពហិរញ្ញវត្ថុដែលមានស្រាប់។** នៅក្នុងឆ្នាំ២០១៤ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំ និងអនុម័តលិខិតបទដ្ឋានគតិយុត្តស្តីពីមុខងារជាអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយកំណត់នូវមុខងារជាជម្រើសគន្លឹះមួយចំនួន ព្រមទាំងជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានការផ្តួចផ្តើមគំនិតកាន់តែច្រើនក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាអាណត្តិទូទៅ និងការបែងចែកនូវការផ្តល់សេវាសាធារណៈ សេវារដ្ឋបាល ក៏ដូចជាមុខងារតាមដាន និងគាំទ្រនានារវាងថ្នាក់រដ្ឋបាលកម្រិតផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ កិច្ចដំណើរការ និងការរៀបចំលិខិតបទដ្ឋាន សម្រាប់ការរៀបចំកិច្ចសន្យាអនុវត្តមុខងារនានារវាងរដ្ឋបាលថ្នាក់ជាតិជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលប្រភេទផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏នឹងត្រូវរៀបចំតាក់តែងផងដែរ។ ជាមួយគ្នានេះដែរ ផែនការអន្តរាគមន៍អភិវឌ្ឍសមត្ថភាពសម្រាប់ជួយជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានគំនិតផ្តួចផ្តើមកាន់តែច្រើនក្នុងក្របខ័ណ្ឌនៃមុខងារជាអាណត្តិទូទៅក៏នឹងត្រូវបានអនុវត្ត ព្រមជាមួយនឹងការសាកល្បងអនុវត្តនូវមុខងារមួយចំនួនផ្សេងទៀតតាមរយៈយន្តការចុះកិច្ចសន្យា (ឬភាពជាដៃគូ) ដែលភាគច្រើនមុខងារទាំងនេះនឹងផ្តោតទៅលើការផ្តល់សេវាសង្គម[4]។ សម្រាប់រយៈពេលវែង ធនធានបន្ថែមលើមូលនិធិក្រុង ស្រុក និងឃុំ សង្កាត់សម្រាប់មុខងារជាអាណត្តិទូទៅនឹងត្រូវបានកៀរគរពីដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា។

---

[3] ឧបករណ៍នានាដែលត្រូវសម្របសម្រួលរួមមាន ឧបករណ៍វិនិយោគសម្រាប់ថ្នាក់ក្រោមជាតិ យន្តការផ្ទេរថវិកាវិនិយោគមានលក្ខខណ្ឌ ចំណូលផ្ទាល់ ការត្រួតពិនិត្យការអនុវត្តតាមលិខិតបទដ្ឋាននានា លិខិតបទដ្ឋានស្តីពីធនធានមនុស្សរបស់ថ្នាក់ក្រោមជាតិ ថវិកាដែលឆ្លើយតបចំពោះយេនឌ័រ ការរៀបចំលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សា ការកែសម្រួល គ.ជ.អ.ប និងការរៀបចំបង្កើតប្រព័ន្ធផែនការនិងថវិកា។

[4] ផលប៉ះពាល់នៃសេវាផ្សេងគ្នា (ដូចជា ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសង្គមចំពោះស្ត្រីនិងជនក្រីក្រមិនទាន់ដឹងពេញលេញនៅឡើយ ប៉ុន្តែគេរំពឹងថា សេវាសង្គមនឹងមានផលប៉ះពាល់ជាច្រើនចំពោះស្ត្រី។

**លទ្ធផលរំពឹងទុកទី១.៤៖ ការសម្របសម្រួល និងការជំរុញគំនិតផ្តួចផ្តើមក្នុងការអភិវឌ្ឍសមត្ថភាព។** សកម្មភាពនៃការអភិវឌ្ឍសមត្ថភាពស្ថិតនៅក្នុងលទ្ធផលរំពឹងទុកជាច្រើននៃ ផអ៣ (ដូចជា សកម្មភាពនៃការអភិវឌ្ឍសមត្ថភាពនានានៅពេលមានការរៀបចំលិខិតបទដ្ឋានគតិយុត្ត ឬបង្កើតជាប្រព័ន្ធថ្មីនានាជាដើម)។ លើសពីនេះទៀត រាជធានី ខេត្តនឹងរៀបចំសកម្មភាពបណ្តុះបណ្តាលជាក់លាក់តាមការចាំបាច់ផ្អែកតាមតម្រូវការជាក់ស្តែងនៅមូលដ្ឋាន។ ដើម្បីបង្កើនការយកចិត្តទុកដាក់ក្នុងឆ្នាំ២០១៤ និងដើម្បីត្រៀមរៀបចំផែនការអនុវត្តដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ យុទ្ធសាស្ត្រ និងក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពនឹងត្រូវបានធ្វើការពិនិត្យ និងកែសម្រួលឡើងវិញនៅត្រីមាសទី១ឆ្នាំ២០១៤ ដោយរួមបញ្ចូលទាំងការពិនិត្យមើលឡើងវិញពីភាពខុសគ្នានៃតម្រូវការសមត្ថភាពរវាងបុរស និងស្ត្រីផងដែរ។

**លទ្ធផលរំពឹងទុកទី១.៥៖ ការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គម។** ការសាកល្បងនូវឧបករណ៍នានាសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គមនឹងត្រូវបានរៀបចំបញ្ចប់នៅត្រីមាសទី១ឆ្នាំ២០១៤ ហើយការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងសៀវភៅណែនាំប្រតិបត្តិការសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គមនឹងត្រូវរៀបចំបញ្ចប់នៅត្រីមាសទី២។ នៅចុងឆ្នាំ២០១៤ គ្រប់ឃុំទាំងអស់នៅក្នុងស្រុកចំនួន២០នឹងបានអនុវត្តសាកល្បងនូវការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ បានចូលរួមក្នុងការសាកល្បងនូវការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ និងបានរៀបចំផែនការសកម្មភាពគណនេយ្យភាពសង្គមសម្រាប់ធ្វើឱ្យប្រសើរនូវការផ្តល់សេវា។ ដូចមានរៀបរាប់នៅក្នុងផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម សកម្មភាពទាំងអស់នេះនឹងពង្រឹងសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន ជាពិសេសស្ត្រី យុវជន និងក្រុមជនងាយរងគ្រោះនានា។

**លទ្ធផលរំពឹងទុកទី១.៦៖ ការអនុវត្តនីតិវិធីគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៃ ផអ៣។** លទ្ធផលនេះ រួមមានការជ្រើសរើសបុគ្គលិកថ្មីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ការអនុវត្តនូវតួនាទី ភារកិច្ចគ្រប់គ្រងទូទៅរបស់លេខាធិការដ្ឋាន ការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំនិងការអនុវត្តកិច្ចព្រមព្រៀងនានា ការចាត់ចែងនិងការគាំទ្រជំនួយបច្ចេកទេសការគ្រប់គ្រងរដ្ឋបាលនិងហិរញ្ញវត្ថុ និងការងារសវនកម្មផ្ទៃក្នុងជាដើម។

**លទ្ធផលរំពឹងទុកទី១.៧៖ ការរៀបចំផែនការអនុវត្តដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ។** នៅខែមករា ឆ្នាំ២០១៤ លក្ខខណ្ឌការងារសម្រាប់ការរៀបចំតាក់តែងផែនការអនុវត្តដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិនឹងត្រូវបានរៀបចំបញ្ចប់ ដោយមានការឯកភាពពីដៃគូអភិវឌ្ឍន៍នានា។ លក្ខខណ្ឌការងារនឹងកំណត់អំពីដំណើរការ និងវិសាលភាពនៃការរៀបចំតាក់តែងផែនការអនុវត្តដំណាក់កាលបន្ទាប់ ការកំណត់អំពីតម្រូវការទីប្រឹក្សាជាតិនិងអន្តរជាតិដែលត្រូវជ្រើសរើស និងការសិក្សានានាដែលត្រូវអនុវត្ត ការកំណត់អំពីការពិនិត្យឡើងវិញនិងការវាយតម្លៃនានាដែលបានគ្រោងរួចហើយសម្រាប់ប្រើប្រាស់ក្នុងការរៀបចំតាក់តែង ព្រមទាំងការកំណត់នូវក្របខ័ណ្ឌពេលវេលានៃការរៀបចំសេចក្តីព្រាងបឋមនៅក្នុងខែឧសភា ឆ្នាំ២០១៤ ការវាយតម្លៃលើសេចក្តីព្រាងនេះនៅក្នុងខែកក្កដា ឆ្នាំ២០១៤ និងការអនុម័តសេចក្តីព្រាងចុងក្រោយនៅក្នុងខែកញ្ញា ឆ្នាំ២០១៤។ ផែនការអនុវត្តដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិនឹងរួមបញ្ចូលនូវការកែសម្រួលក្របខ័ណ្ឌលទ្ធផល និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រផងដែរ។

**លទ្ធផលរំពឹងទុកទី១.៨៖ ការពង្រឹងការអនុវត្តប្រព័ន្ធ និងកិច្ចដំណើរការគ្រប់គ្រងការអនុវត្តការងារ។** ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងការអនុវត្តការងារ ត្រឹមខែមីនា ឆ្នាំ២០១៤នឹងត្រូវអនុវត្តឱ្យបានចប់នូវការពិនិត្យឡើងវិញអំពីតួនាទីរបស់ គ.ជ.អ.ប ក្នុងការគ្រប់គ្រងការអនុវត្តការងារ ការសម្របសម្រួលជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាល

ស្ដីពីបញ្ហាគោលនយោបាយជាយុទ្ធសាស្ត្រនានា ការធានានូវការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពនៃអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប និងការធានាឱ្យបាននូវការអនុវត្តសេចក្ដីសម្រេចនានាដែលបានអនុម័ត។ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងធានាឱ្យមានកិច្ចប្រជុំសម្របសម្រួលជាមួយស្ថាប័នអនុវត្ត ផអ៣ ប្រចាំត្រីមាសនៅក្នុងឆ្នាំ២០១៤ ដោយមានរបៀបវារៈច្បាស់លាស់ មានការកត់ត្រាពីចំណុចព្រមព្រៀងគ្នា មានចំណុចដៅ និងផែនការសកម្មភាពដែលមានកំណត់ពេលវេលាជាក់លាក់សម្រាប់ការអនុវត្តចំណុចនានាដែលបានឯកភាពគ្នាក្នុងអង្គប្រជុំ។

**លទ្ធផលរំពឹងទុកទី១.៩៖ ការរៀបចំប្រព័ន្ធតាមដាននិងវាយតម្លៃ និងការត្រួតពិនិត្យ ការវាយតម្លៃ ផអ៣។** នៅក្នុងឆ្នាំ២០១៤ នឹងមានរៀបចំរបាយការណ៍អង្កេតស្ដីពីអភិបាលកិច្ច និងការវាយតម្លៃសមត្ថភាពដែលវាស់វែងអំពីការផ្លាស់ប្ដូរនានាធៀបនឹងទិន្នន័យដើមគ្រាក្នុងឆ្នាំ២០១១។ ប្រព័ន្ធតាមដាននិងវាយតម្លៃក្រុង ស្រុកនឹងត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់នៅក្នុងក្រុង ស្រុកគោលដៅមួយចំនួន។ នៅតាមអនុកម្មវិធីនានានឹងមានការសម្របសម្រួលឱ្យរៀបចំយុទ្ធសាស្ត្រតាមដាននិងវាយតម្លៃ និងផែនការសកម្មភាពសម្រាប់អនុវត្តការងារនេះ។ ជាមួយគ្នានេះដែរ ការវាយតម្លៃនានាអំពីផលប៉ះពាល់ (ពិនិត្យមើលលើភាពក្រីក្រ ជីវភាពរស់នៅរួមទាំងផលប៉ះពាល់ទៅលើស្ត្រី) នឹងត្រូវបានអនុវត្ត។

**លទ្ធផលរំពឹងទុកទី១.១០៖ ការពង្រឹងប្រព័ន្ធ និងសមត្ថភាពព័ត៌មានវិទ្យា។** នៅក្នុងឆ្នាំ២០១៤ ប្រព័ន្ធទិន្នន័យផែនការសកម្មភាពនិងថវិការបស់ គ.ជ.អ.ប (NAD) ដែលប្រើសម្រាប់តាមដានការអនុវត្ត ផអ៣ នឹងត្រូវបានប្រើប្រាស់សម្រាប់គម្រោងដាច់ដោយឡែកមួយចំនួនផងដែរដូចជា គម្រោង LASED, One Window Service, TS-PRSDP, ACES, UNFPA, LGCC, និង SNC Scale-up។ ការងារពាក់ព័ន្ធនឹងការផ្ទុកទិន្នន័យនិងការកំណត់ស្ដង់ដារសូចនាកររួមដែលមាននៅក្នុងប្រព័ន្ធទិន្នន័យទាំង៨ដែលកំពុងប្រើប្រាស់បច្ចុប្បន្ន (PID, CDB, DIS ជាដើម) នឹងត្រូវបានបន្តអនុវត្ត។ ប្រព័ន្ធទាំងនេះនឹងត្រូវបានពិនិត្យឡើងវិញ ដើម្បីជាធាតុចូលមួយសម្រាប់ការរៀបចំផែនការអនុវត្តដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ។

**លទ្ធផលរំពឹងទុកទី១.១១៖ ការអនុវត្តយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ការអប់រំ និងទំនាក់ទំនងរបស់ផអ៣។** ទូរទស្សន៍ វិទ្យុ ឯកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀតនានានឹងត្រូវបានប្រើប្រាស់សម្រាប់ជូនដំណឹងដល់បុគ្គលិក មន្ត្រីរាជការ និងប្រជាពលរដ្ឋ (ដោយត្រូវពិចារណាអំពីតម្រូវការព័ត៌មានខុសគ្នាតាមយេនឌ័រ) ស្ដីពីកិច្ចខិតខំប្រឹងប្រែងក្នុងកិច្ចដំណើរការកំណែទម្រង់រដ្ឋបាលមូលដ្ឋាន។ ជាមួយគ្នានេះដែរ នឹងមានការពិនិត្យមើលពីលទ្ធភាពនៃការប្រើប្រាស់បច្ចេកទេសទីផ្សារសង្គមសម្រាប់យុទ្ធនាការនេះ។

**លទ្ធផលរំពឹងទុកទី១.១២៖ ការពង្រឹងសមត្ថភាពស្ថាប័នក្រុមប្រឹក្សា និងសមាជិកក្រុមប្រឹក្សា។** លទ្ធផលរំពឹងទុកនេះពាក់ព័ន្ធនឹងការរៀបចំ និងដាក់ឱ្យអនុវត្តនូវនីតិវិធីប្រតិបត្តិរបស់ក្រុមប្រឹក្សា (រួមទាំងឯកសារបច្ចេកទេសស្ដីពីការចូលរួមរបស់ប្រជាពលរដ្ឋ ទំនាក់ទំនងផ្ទៃក្នុងរវាងរដ្ឋបាលនីមួយៗនិងអន្តររដ្ឋបាល និងការអភិវឌ្ឍសេដ្ឋកិច្ចតំបន់ដែលកិច្ចការទាំងនេះត្រូវបានរៀបចំដោយមានកិច្ចសហការជាមួយគម្រោង EU-SPACE) និងការបន្តអនុវត្តនូវការផ្ដល់សេវាសម្របសម្រួលនិងការប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សា។ ជាមួយគ្នានេះដែរ ដើម្បីផ្ដល់ជាធាតុចូលសម្រាប់ការរៀបចំតាក់តែងផែនការអនុវត្តដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ កិច្ចដំណើរការផ្ដល់សេវាសម្របសម្រួលនិងប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សានឹងត្រូវបានពិនិត្យឡើងវិញ និងធ្វើការកែសម្រួលដោយរួមបញ្ចូលទាំងបញ្ហាប្រឈមនានាដែលជួបប្រទះក្នុងការជ្រើសរើសមន្ត្រីសម្របសម្រួលជាស្ត្រី និងកម្រិតនៃការសម្របសម្រួលនិងប្រឹក្សាយោបល់សម្រាប់ឆ្លើយតបតម្រូវការនានារបស់ស្ត្រី។

**លទ្ធផលរំពឹងទុកទី១.១៣៖ ការរៀបចំបញ្ចប់យុទ្ធសាស្ត្រសម្រាប់ពង្រឹងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា និងការអនុវត្តតួនាទីភារកិច្ចរបស់មន្ត្រីរដ្ឋបាលនៅក្នុង អាណត្តិទី២នៃក្រុមប្រឹក្សាក្រុង ស្រុក។** ការបែងចែកការទទួលខុសត្រូវឱ្យមានលក្ខណៈសមស្រប (តុល្យភាពអំណាច) រវាងក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានបន្តពង្រឹង។ លទ្ធផលរំពឹកទុកនេះនឹងផ្តោតទៅលើការពិនិត្យឡើងវិញនូវកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងការរៀបចំលិខិតបទដ្ឋាននានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅត្រីមាសទី២នៃឆ្នាំ២០១៤ ស្របពេលជាមួយនឹងការរៀបចំតាក់តែងផែនការអនុវត្តដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ នឹងមានការរៀបចំនិងអនុម័តយុទ្ធសាស្ត្រមួយដែលផ្តោតជាសំខាន់ទៅលើការពង្រឹងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងអាណតិទី២របស់ខ្លួន។ សកម្មភាពជាក់លាក់មួយចំនួនដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រនោះនឹងត្រូវអនុវត្តនៅក្នុងឆ្នាំនេះ។ គំរូវិធានផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុកក៏នឹងត្រូវបានរៀបចំបញ្ចប់ អនុម័ត និងដាក់ឱ្យប្រើប្រាស់ជាបណ្តើរៗ ដោយមានការជួយគាំទ្រពីមន្ត្រីសម្របសម្រួលរបស់ក្រុមប្រឹក្សា។

**លទ្ធផលរំពឹងទុកទី១.១៤៖ ការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លិខិតបទដ្ឋានគតិយុត្ត សៀវភៅណែនាំ សម្ភារៈបណ្តុះបណ្តាល និងសកម្មភាពផ្សេងៗ ព្រមទាំងការពង្រឹងសមត្ថភាពបញ្ជ្រាបយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។** លទ្ធផលរំពឹងទុកនេះពាក់ព័ន្ធជាមួយនឹងការពិនិត្យមើលឡើងវិញនូវលិខិតបទដ្ឋានគតិយុត្ត ការបញ្ជ្រាបយុទ្ធសាស្ត្រយេនឌ័រទៅក្នុងសកម្មភាពទាំងឡាយនៃ ផអព និងការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាថា យុទ្ធសាស្ត្រយេនឌ័រត្រូវបានបញ្ជ្រាបនៅថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ ចំណេះដឹងអំពីអនុសញ្ញា CEDAW និងសិទ្ធិស្ត្រីនឹងត្រូវបានលើកកម្ពស់បន្ថែម។ ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មយេនឌ័រដែលនឹងត្រូវបានរៀបចំបញ្ចប់នៅខែមករា ឆ្នាំ២០១៤ ផែនការការងារពាក់ព័ន្ធយេនឌ័រសម្រាប់ឆ្នាំ២០១៤ នឹងត្រូវបានរៀបចំដោយមានកំណត់អំពីសកម្មភាពជាក់លាក់ដែលត្រូវអនុវត្តដោយស្ថាប័នអនុវត្ត ផអព នីមួយៗ ព្រមទាំងការរៀបចំនូវសៀវភៅណែនាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីបញ្ហានានាពាក់ព័ន្ធនឹងយេនឌ័រផងដែរ។ អនុសាសន៍នៃសវនកម្មយេនឌ័រក៏នឹងត្រូវយកមកប្រើប្រាស់សម្រាប់ការរៀបចំតាក់តែងផែនការអនុវត្តដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ។

**លទ្ធផលរំពឹងទុកទី១.១៥៖ ការពង្រឹងកិច្ចដំណើរការ និងការផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រការផ្តល់សេវាសង្គមរបស់ឃុំ សង្កាត់។** អង្គការ UNICEF នឹងបន្តការគាំទ្ររបស់ខ្លួន[5] ដល់ឃុំ សង្កាត់ ដើម្បីជំរុញឱ្យការផ្តល់សេវាសង្គមកាន់តែមានភាពល្អប្រសើរឡើង (ដូចជា ការផ្តល់សេវាពាក់ព័ន្ធនឹងមត្តេយ្យសហគមន៍ និងការគាំទ្រដល់គ្រួសារក្រីក្រជាដើម)។

**លទ្ធផលរំពឹងទុកទី១.១៦៖ ការពង្រឹងភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ។** ដើម្បីលើកកម្ពស់ភាពស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុរបស់រដ្ឋបាលថ្នាក់មូលដ្ឋាន គម្រោង LGCC ដែលគាំទ្រដោយមូលនិធិសម្រាប់អភិវឌ្ឍមូលធនរបស់អង្គការសហប្រជាជាតិ (UNCDF) ត្រូវបានរៀបចំ និងអនុវត្តការសាកល្បងទ្រង់ទ្រាយតូច[6]ក្នុងក្របខ័ណ្ឌនៃកម្មវិធីវិនិយោគឃុំ សង្កាត់។ គម្រោង LGCC នឹង៖

- ធ្វើសមាហរណកម្មលើគ្រប់វិស័យនូវការកសាងយុទ្ធសាស្ត្រនៃភាពធន់នឹងការប្រែប្រួលអាកាសធាតុ ចូលក្នុងដំណើរការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគនៅក្នុងខេត្តចំនួន២ ស្រុកចំនួន៧ និងនៅក្នុងឃុំ សង្កាត់ចំនួន៣០។

[5] ការគាំទ្ររបស់ UNICEF ដល់ឃុំ សង្កាត់មានចំនួន៣៤៧។ ការផ្តល់សេវាសង្គមផ្តោតជាសំខាន់លើតម្រូវការនៅមូលដ្ឋានរបស់ស្ត្រីនិងកុមារ។

[6] គម្រោងជាក់លាក់រួមមានផ្លូវ ប្រព័ន្ធធារាសាស្ត្រ ប្រឡាយ អាងស្តុកទឹក ការដាំដុះ និងការងារអនាម័យ។

- រួមចំណែកផ្តល់ហិរញ្ញប្បទានគាំទ្រការអនុវត្តគម្រោង ដែលអនុវត្តក្នុងប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងក្រុងស្រុកចំនួន១០ និងនៅឃុំ សង្កាត់យ៉ាងតិចចំនួន២០ឃុំ សង្កាត់ក្នុងវដ្តថវិកាចំនួន២ ។
- រៀបចំបង្កើតនូវបរិយាកាសផ្នែកច្បាប់មួយ ដើម្បីជំរុញដល់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

បន្ថែមលើនេះ សកម្មភាពនៃការប្រែប្រួលអាកាសធាតុនឹងត្រូវពង្រីកដំណើរការរបស់ខ្លួន ដោយបញ្ចូលទៅក្នុងប្រព័ន្ធកសាងផែនការនិងថវិការបស់ថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់មូលនិធិរបស់គម្រោងបញ្ជ្រាបយុទ្ធសាស្ត្របំរែបំរួលអាកាសធាតុក្នុងដំណើរការកសាងផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNC Scale-up) ដែលគាំទ្រដោយ UNDP ។

**លទ្ធផលរំពឹងទុកទី១.១៧៖ ការអនុវត្តគម្រោងការបែងចែកដីធ្លី សម្រាប់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច (LASED) ។**

**លទ្ធផលរំពឹងទុកទី១.១៨៖ ការអនុវត្តគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់បឹងទន្លេសាប (TS-PRSDP) ។**

**លទ្ធផលរំពឹងទុក១.១៩៖ ការគ្រប់គ្រងអនុកម្មវិធីទី១ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។** ថវិកាប្រតិបត្តិការនឹងត្រូវផ្តល់ដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌនៅក្នុងត្រីមាសទី១នៃឆ្នាំ២០១៤ ដើម្បីឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌមានលទ្ធភាពជ្រើសរើសបុគ្គលិកកិច្ចសន្យាតាមតម្រូវការចាំបាច់របស់ក្រុង ស្រុក ខណ្ឌ ដើម្បីគាំទ្រដល់សកម្មភាពជាយុទ្ធសាស្ត្រទាំងឡាយណាដែលមិនអាចរ៉ាប់រងបានដោយថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ ។

### ១.៣. ថវិកានៃអនុកម្មវិធីទី១

នៅឆ្នាំ២០១៤ ថវិកា ផ.ស.ថ សម្រាប់អនុកម្មវិធីទី១មានដូចតទៅ៖

**តារាងទី៥: ថវិកាតាមលទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី១**

| កូដ | លទ្ធផលរំពឹងទុក | កញ្ចប់រួម | ផ្សេងទៀត | សរុប | ប្រភព |
|---|---|---|---|---|---|
| 1.1 | ការសម្របសម្រួល និងគាំទ្រដល់ការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តចំនួន១០របស់អនុកម្មវិធីនានា និងការពិនិត្យឡើងវិញអំពីផលប៉ះពាល់ចំពោះយេនឌ័រ | $164,800 | $0 | $164,800 | Basket |
| 1.2 | ការផ្ទេរមុខងារក្នុងលក្ខណៈជាការសាកល្បង ឬជាអចិន្ត្រៃយ៍ | $160,000 | $0 | $160,000 | Basket, EU-SPACE in kind |
| 1.3 | ការកំណត់ និងសាកល្បងនូវមុខងារជាជម្រើស (អាណត្តិទូទៅ) ដោយប្រើប្រាស់មូលនិធិមានភ្ជាប់លក្ខខណ្ឌ និងប្រភពធនធានហិរញ្ញវត្ថុដែលមានស្រាប់ | $5,000 | $500,000 | $505,000 | Basket, AUSAID, EU-SPACE in kind |
| 1.4 | ការសម្របសម្រួល និងការជំរុញគំនិតផ្តួចផ្តើមអភិវឌ្ឍសមត្ថភាពឱ្យកាន់តែល្អប្រសើរជាងមុន | $93,800 | $0 | $93,800 | Basket |
| 1.5 | ការអនុវត្តផែនការសកម្មភាពស្តីពីគណនេយ្យភាពសង្គម | $120,000 | $0 | $120,000 | Basket |
| 1.6 | ការអនុវត្តនីតិវិធីគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៃផអ៣ | $417,850 | $0 | $417,850 | Basket |
| 1.7 | ការរៀបចំផែនការអនុវត្តជំហានបន្ទាប់នៃកម្មវិធីជាតិ | $250,000 | $0 | $250,000 | Basket |
| 1.8 | ការពង្រឹងកិច្ចដំណើរការ និងប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារ | $0 | $0 | $0 | Basket |
| 1.9 | ការអភិវឌ្ឍប្រព័ន្ធតាមដាននិងវាយតម្លៃ និងការតាមដាន និងការ | $202,960 | $0 | $202,960 | Basket |

| កូដ | លទ្ធផលរំពឹងទុក | កញ្ចប់រួម | ផ្សេងទៀត | សរុប | ប្រភព |
|---|---|---|---|---|---|
| | វាយតម្លៃ ផអព ។ | | | | |
| 1.10 | ការពង្រឹងប្រព័ន្ធព័ត៌មានវិទ្យា និងសមត្ថភាពព័ត៌មានវិទ្យា | $79,900 | $0 | $79,900 | Basket |
| 1.11 | ការអនុវត្តយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ការអប់រំ និងទំនាក់ទំនងស្តីពី ផអព ។ | $67,790 | $0 | $67,790 | Basket |
| 1.12 | ការពង្រឹងសមត្ថភាពស្ថាប័នក្រុមប្រឹក្សា និងសមាជិកក្រុមប្រឹក្សា ។ | $125,000 | $0 | $125,000 | Basket, EU-SPACE in kind |
| 1.13 | ការរៀបចំបញ្ចប់យុទ្ធសាស្ត្រសម្រាប់ការពង្រឹងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា ពោលគឺកិច្ចការរដ្ឋបាលនៅក្នុងអាណត្តិទី២របស់ក្រុមប្រឹក្សាក្រុង ស្រុក ។ | $0 | $0 | $0 | Basket, EU-SPACE in kind |
| 1.14 | ការបញ្ជ្រាបយុទ្ធសាស្ត្រយេនឌ័រនៅក្នុងគោលនយោបាយសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លិខិតបទដ្ឋានគតិយុត្ត សៀវភៅណែនាំ សេចក្តីណែនាំ សម្ភារៈបណ្តុះបណ្តាលនិងសកម្មភាពផ្សេងៗ ព្រមទាំងការពង្រឹងសមត្ថភាពបញ្ជ្រាបយេនឌ័រនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ។ | $49,036 | $34,000 | $83,036 | Basket, UN Women |
| 1.15 | ការពង្រឹងកិច្ចដំណើរការ និងការផ្តល់ហិរញ្ញប្បទានគាំទ្រការផ្តល់សេវាសង្គមនៅថ្នាក់ឃុំសង្កាត់ ។ | $0 | $145,000 | $145,000 | UNICEF |
| 1.16 | ការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ ។ | $0 | $1,077,920 | $1,077,920 | LGCCII, SC |
| 1.17 | ការអនុវត្តគម្រោង LASED ។ | $0 | $1,056,402 | $1,056,402 | LASED |
| 1.18 | ការអនុវត្តគម្រោង TS-PRSDP ។ | $0 | $14,924,204 | $14,924,204 | TSPRSDP |
| 1.19 | ការគ្រប់គ្រងអនុកម្មវិធីទី១ប្រកបដោយប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ | $3,099,163 | $125,000 | $3,224,163 | Basket, RGC |
| | **សរុបថវិកា** | **$4,835,299** | **$17,862,525** | **$22,697,824** | |

# ជំពូកទី២ ៖ ការរៀបចំបុគ្គលិក ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រ
# ហេដ្ឋារចនាសម្ព័ន្ធក្រុង ស្រុក (អនុកម្មវិធីទី២)

## ២.១. សេចក្តីផ្តើម

អនុកម្មវិធីទី២មានគោលបំណងអភិវឌ្ឍប្រព័ន្ធប្រតិបត្តិការ និងសមត្ថភាពដល់អង្គប្រតិបត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (គណៈអភិបាល និងមន្ត្រីរដ្ឋបាល) ដើម្បីឱ្យពួកគាត់អាច (១) អនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព និង (២) ទទួលយកជាបណ្តើរៗនូវការទទួលខុសត្រូវក្នុងការត្រួតពិនិត្យមើល និងអនុវត្តនូវមុខងារនានាដែលបានប្រគល់ឱ្យដោយថ្នាក់ជាតិ។ អនុកម្មវិធីទី២អនុវត្តដោយក្រសួងមហាផ្ទៃ។ សមិទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី២មានរៀបរាប់ដូចខាងក្រោម៖

**ប្រអប់ទី៣៖ សមិទ្ធផលរំពឹងទុករបស់ផអ៣នៃអនុកម្មវិធីទី២**

**សមិទ្ធផលរំពឹងទុក ៖**

- គណៈអភិបាល និងមន្ត្រីរដ្ឋបាលមានការយល់ដឹង និងមានចំណេះដឹងប្រសើរជាងមុន [2.2-2.5]។
- គណៈអភិបាល និងមន្ត្រីរដ្ឋបាលអាចអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបានប្រសើរជាងមុន [2.2-2.6]។
- រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាបានល្អជាងមុន [2.6]។
- រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង និងចាត់ចែងបានប្រសើរជាងមុន (រាប់បញ្ចូលនូវមុខងារទាំងអស់ លើកលែងតែមុខងារពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការរបស់ក្រុមប្រឹក្សា) [2.2-2.6]។
- អភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានប្រសើរជាងមុន (កាន់តែមានតម្លាភាព ការចូលរួម គណនេយ្យភាព និងកាត់បន្ថយអំពើពុករលួយ...) [2.2-2.6]។
- ការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានល្អជាងមុន (ដោយសារមានការគ្រប់គ្រង និងអភិបាលកិច្ច ល្អជាងមុន ហើយមន្ត្រីម្នាក់ៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពខ្ពស់ជាងមុន) (លទ្ធផលរំពឹងទុកទាំងអស់)។

**សម្គាល់ ៖** លទ្ធផលរំពឹងទុកនានាដែលរួមចំណែកដោយផ្ទាល់ដល់សមិទ្ធផលនីមួយៗដូចមានបញ្ជាក់ក្នុងវង់ក្រចក។ លទ្ធផលរំពឹងទុកមួយអាចរួមចំណែកដល់សមិទ្ធផលច្រើន។ សមិទ្ធផលទាំងអស់គ្របដណ្តប់ក្នុងរយៈពេលផអ៣ទាំងមូល។

## ២.២. លទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី២

**លទ្ធផលរំពឹងទុកទី២.១៖ ការរៀបចំបញ្ចប់នូវការកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។** ចំពោះអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៅពេលរចនាសម្ព័ន្ធដែលបានកែសម្រួលត្រូវបានអនុម័ត ការងារបន្ទាប់ គឺត្រូវផ្តោតលើការបង្កើតទម្រង់របាយការណ៍ និងខ្សែគណនេយ្យភាព តារាងបញ្ជីការងារ មុខតំណែង និងការពិនិត្យឡើងវិញលើលក្ខខណ្ឌការងារនានា។ ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ ការកែលម្អរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងការងារនឹងត្រូវធ្វើឡើងជាប្រចាំ។

**លទ្ធផលរំពឹងទុកទី២.២៖ ការរៀបចំតាក់តែង និងដាក់ឱ្យអនុវត្តនូវសៀវភៅណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត។** ការងារនេះនឹងអនុវត្តដោយសហការជាមួយអនុកម្មវិធីទី៥ ដោយរាប់បញ្ចូលទាំងការពិនិត្យឡើងវិញនូវដំណើរការដែលមានស្រាប់ការរៀបចំសៀវភៅណែនាំ និងការបណ្តុះបណ្តាល។

**លទ្ធផលរំពឹងទុកទី២.៣៖ ការកែសម្រួល និងការដាក់ឱ្យប្រើប្រាស់នូវទម្រង់របាយការណ៍ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។**

**លទ្ធផលរំពឹងទុកទី២.៤៖ ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីប្រតិបត្តិការថ្នាក់ក្រុង ស្រុកដោយរួមបញ្ចូលកិច្ចការរដ្ឋបាល ការគ្រប់គ្រងធនធានមនុស្ស និងការអនុវត្តគម្រោង។** សៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិការថ្នាក់ក្រុង ស្រុក នឹងត្រូវបានរៀបចំបញ្ចប់ក្នុងដើមត្រីមាសទី២ និងដាក់ឱ្យប្រើប្រាស់តាមរយៈកម្មវិធីបណ្តុះបណ្តាលដល់គ្រប់ក្រុង ស្រុក។ សៀវភៅណែនាំនេះមានអធិប្បាយលម្អិតអំពីមុខងារសំខាន់ៗរបស់ការិយាល័យនីមួយៗនៅថ្នាក់ក្រុង ស្រុក[7]។

**លទ្ធផលរំពឹងទុកទី២.៥៖ ការដាក់ឱ្យអនុវត្តនូវកិច្ចដំណើរការនានាសម្រាប់ការគ្រប់គ្រងធនធានមនុស្សដែលបានរៀបចំដោយអនុកម្មវិធីទី៣។** ការងារនេះរួមមាន ការបណ្តុះបណ្តាលអំពីអនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាដែលបានរៀបចំដោយអនុកម្មវិធីទី៣ (ពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានមនុស្ស) និងការបណ្តុះបណ្តាលស្តីពីការអនុវត្តនូវកិច្ចដំណើរការវាយតម្លៃការបំពេញការងាររបស់មន្ត្រី។ កិច្ចដំណើរការនៃការវាយតម្លៃការបំពេញការងារនេះនឹងត្រូវអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់នៅក្នុងឆ្នាំ២០១៤។

**លទ្ធផលរំពឹងទុកទី២.៦៖ ការអនុវត្តដំណើរការអភិវឌ្ឍស្ថាប័ន។** បច្ចុប្បន្ន ការអភិវឌ្ឍស្ថាប័នត្រូវបានអនុវត្តនៅគ្រប់ក្រុង ស្រុក ខណ្ឌ (រួមទាំងការវាយតម្លៃដើម្បីកំណត់តម្រូវការអភិវឌ្ឍស្ថាប័ន និងការរៀបចំផែនការអភិវឌ្ឍស្ថាប័ន)។ នៅក្នុងឆ្នាំ២០១៤ លទ្ធផលនៃការអភិវឌ្ឍស្ថាប័ននឹងត្រូវធ្វើការវាយតម្លៃ កិច្ចដំណើរការអភិវឌ្ឍស្ថាប័ននឹងត្រូវបានអនុវត្តដោយរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ហើយធនធាននានានឹងត្រូវបានផ្តល់ឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីអនុវត្តផែនការអភិវឌ្ឍស្ថាប័នរបស់ខ្លួន។

**លទ្ធផលរំពឹងទុកទី២.៧៖ កិច្ចដំណើរការអធិការកិច្ច ឬការត្រួតពិនិត្យមើលពីលើត្រូវបានរៀបចំ និងអនុវត្តសាកល្បងនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌចំនួន១២។** នៅក្នុងឆមាសទី១នៃឆ្នាំ២០១៤ កិច្ចដំណើរការអធិការកិច្ច និងការរៀបចំឡើងវិញនូវស្ថាប័នសម្រាប់ការងារនេះនឹងត្រូវបានអនុវត្ត ។ អធិការកិច្ចនឹងធ្វើនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ការរៀបចំកិច្ចដំណើរការអធិការកិច្ច ឬការត្រួតពិនិត្យមើលពីលើនេះរួមមាន ការកំណត់ភ័ស្តុតាងពាក់ព័ន្ធដែលចាំបាច់នានាសម្រាប់ធ្វើវាយតម្លៃប្រកបដោយភាពមិនលំអៀង ការកំណត់នូវវិសាលភាព និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ការធ្វើអធិការកិច្ច ការរៀបចំបង្កើតនីតិវិធី ព្រមទាំងការបញ្ចូលទិន្នន័យ និងការបង្កើតប្រព័ន្ធដាក់ពិន្ទុ។ មន្ត្រីអធិការកិច្ចនៃក្រសួងមហាផ្ទៃ និងរាជធានី ខេត្ត នឹងទទួលបានការបណ្តុះបណ្តាល។ ការធ្វើអធិការកិច្ចសាកល្បងនឹងត្រូវអនុវត្តក្នុងត្រីមាសទី៣ ហើយកិច្ចដំណើរការនឹងត្រូវបានវាយតម្លៃ និងកែសម្រួលឡើងវិញនៅឆ្នាំ២០១៥។

**លទ្ធផលរំពឹងទុកទី២.៨៖ ការពិនិត្យឡើងវិញ ការកែសម្រួល និងការអនុវត្តនូវយន្តការដោះស្រាយវិវាទនៅមូលដ្ឋានដែលជាផ្នែកមួយនៃការងាររបស់ក្រុមការងារគណនេយ្យភាពថ្នាក់រាជធានី ខេត្ត។**

**លទ្ធផលរំពឹងទុកទី២.៩៖ ការត្រួតពិនិត្យលើការគ្រប់គ្រង និងការបំពេញការងាររបស់ថ្នាក់ក្រោមជាតិត្រូវបានអនុវត្តជាប្រចាំ ហើយលទ្ធផលនៃការត្រួតពិនិត្យត្រូវបានផ្សព្វផ្សាយជាសាធារណៈ។** ក្នុងលទ្ធផលរំពឹងទុកនេះមានកិច្ចការជាច្រើនដែលត្រូវអនុវត្តដែលក្នុងនោះរួមមាន ការរៀបចំសិក្ខាសាលាដើម្បីផ្សព្វផ្សាយអំពីលទ្ធផលនៃការវាយតម្លៃលើការគ្រប់គ្រង និងការបំពេញភារកិច្ចនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផងដែរ។

[7] សេចក្តីព្រាងនានាដូចជា ការគាំទ្រឃុំ សង្កាត់ ការចូលរួមរបស់ពលរដ្ឋ ដីកានិងសេចក្តីសម្រេច កិច្ចប្រជុំ រដ្ឋបាលទូទៅ ការគ្រប់គ្រងការិយាល័យ ការគ្រប់គ្រងបុគ្គលិក និងហិរញ្ញវត្ថុ ការរៀបចំគម្រោងនិងការបញ្ជាក់បច្ចេកទេស លទ្ធកម្មនិងការគ្រប់គ្រងកិច្ចសន្យា និងការត្រួតពិនិត្យនិងវាយតម្លៃគម្រោង។

**លទ្ធផលរំពឹងទុកទី២.១០៖ ការពង្រឹងការផ្តល់សេវាសង្គម និងគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារនៅថ្នាក់ខេត្ត ក្រុង ស្រុក និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (UNFPA)។** ការគាំទ្រហិរញ្ញវត្ថុនឹងត្រូវផ្តល់ដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) (ថវិកាចំនួន៣.៥០០ដុល្លារសម្រាប់ខេត្តគោលដៅចំនួន៧ ថវិកាចំនួន២៤.២៤០ដុល្លារសម្រាប់ស្រុកគោលដៅចំនួន៤៨) និងថវិកាចំនួន១៧៣.៥២០ដុល្លារសម្រាប់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ (គ.ក.ន.ក) ចំនួន៣៤៦ឃុំ ដើម្បីលើកកម្ពស់អន្តរាគមន៍ពាក់ព័ន្ធនឹងសុខភាពបន្តពូជដូចជា ការរៀបចំផែនការគ្រួសារ និងបញ្ហាយេនឌ័រ។ សកម្មភាពបន្ថែមផ្សេងទៀតមានដូចជា ការបណ្តុះបណ្តាលមន្ត្រីថ្នាក់ខេត្ត និងស្រុក និងការត្រួតពិនិត្យការបំពេញការងារជាប្រចាំ។

**លទ្ធផលរំពឹងទុកទី២.១១៖ ការពង្រឹងការផ្តល់សេវាសង្គមនៅថ្នាក់ក្រោមជាតិ (គាំទ្រមូលនិធិដោយ UNICEF)។** តាមរយៈមូលនិធិគាំទ្រនេះ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាននឹងពង្រឹង ៖ ១) ការរៀបចំផែនការ ២) ការគ្រប់គ្រងគ្រោះមហន្តរាយ ៣) ការចុះបញ្ជីអត្រានុកូលដ្ឋាន ៤) ការផ្តល់សេវាសង្គម និង ៥) សមត្ថភាពមន្ត្រីបង្គោលផ្នែកពិការភាពនៅថ្នាក់ឃុំ។ សម្រាប់រាជធានីភ្នំពេញនឹងមានការរៀបចំកម្មវិធីផ្តួចផ្តើមថ្មីនានាសម្រាប់ប្រជាពលរដ្ឋក្រីក្រនៅទីប្រជុំជន។

**លទ្ធផលរំពឹងទុកទី២.១២៖ ការសាងសង់សាលាស្រុកចំនួន៤០។** អគារ និងការិយាល័យបំពេញការងារនៅថ្នាក់រាជធានី ខេត្តភាគច្រើនមានលក្ខណៈល្អសមរម្យហើយ។ ដោយឡែក អគារ និងការិយាល័យបំពេញការងារនៅថ្នាក់ក្រុង ស្រុកភាគច្រើនតម្រូវឱ្យមានការសាងសង់ថ្មី ឬជួសជុលឡើងវិញ។ ដោយមានការគាំទ្រពីធនាគារអភិវឌ្ឍអាស៊ី គម្រោងមួយត្រូវបានរៀបចំឡើងក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវអគារ និងការិយាល័យបំពេញការងារនៃសាលាស្រុកមួយចំនួន (កិច្ចការ នេះរួមបញ្ចូលទាំងការសិក្សាលទ្ធភាព ការរៀបចំបញ្ជីអាទិភាព គំនូរប្លង់បឋម និងថវិកាប៉ាន់ស្មាន់សម្រាប់ការសាងសង់ ឬការជួសជុល និងការបំពាក់សម្ភារៈ[8])។ ថវិកាសម្រាប់ឆ្នាំ២០១៤មានចំនួន៣.៥លានដុល្លារអាមេរិក។

**លទ្ធផលរំពឹងទុកទី២.១៣៖ ការពង្រឹង និងគាំទ្រការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅក្រុង ស្រុក ខណ្ឌគោលដៅចំនួន៣៧ (OWSO)។** កិច្ចការនេះរួមមាន៖ ១) ការបន្តសាងសង់អគារការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅក្នុងខណ្ឌចំនួន៤ (ខណ្ឌ៧មករា ខណ្ឌឫស្សីកែវ ខណ្ឌមានជ័យ និងខណ្ឌដង្កោ) ២) ការគាំទ្រចំណាយប្រតិបត្តិការ និងប្រាក់ឧបត្ថម្ភសម្រាប់មន្ត្រីការិយាល័យច្រកចេញចូលតែមួយ និង ៣) ការអនុវត្តសកម្មភាពនៃការចូលរួមរបស់ប្រជាជន និងការផ្សព្វផ្សាយ។

**លទ្ធផលរំពឹងទុកទី២.១៤៖ ការគ្រប់គ្រងអនុកម្មវិធីទី២ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។** ក្រៅពីការងារបុគ្គលិក និងប្រតិបត្តិការសម្រាប់អនុកម្មវិធីទី២ លទ្ធផលរំពឹងទុកនេះក៏បានបញ្ចូលនូវចំណាយប្រតិបត្តិការនានារបស់ការិយាល័យច្រកចេញចូលតែមួយ និងការត្រួតពិនិត្យជាប្រចាំនូវផែនការអភិវឌ្ឍ គម្រោង និងថវិកានានារបស់ថ្នាក់ក្រោមជាតិ។

[8] នៅឆ្នាំ២០១២ គេបានវាយតម្លៃស្ថានភាពនៃការិយាល័យទាំងនេះ។ ថវិកាសម្រាប់សាងសង់សាលាឃុំ សង្កាត់គឺជាថវិការបស់រាជរដ្ឋាភិបាល។

## ២.៣ ថវិកានៃអនុកម្មវិធីទី២

**តារាងទី៦៖ ថវិកាតាមលទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី២ (គិតជាដុល្លារ)**

| កូដ | លទ្ធផលរំពឹងទុក | កញ្ចប់រួម | ផ្សេងទៀត | សរុប | ប្រភព |
|---|---|---|---|---|---|
| 2.1 | ការរៀបចំបញ្ចប់នូវការកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។ | $4,500 | $0 | $4,500 | Basket |
| 2.2 | ការតាក់តែង និងដាក់ឱ្យអនុវត្តសៀវភៅណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត ។ | $38,580 | $0 | $38,580 | Basket |
| 2.3 | ការពិនិត្យឡើងវិញនូវទម្រង់របាយការណ៍ថ្នាក់ក្រោមជាតិ | $6,350 | $0 | $6,350 | Basket |
| 2.4 | ការរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវនីតិវិធីប្រតិបត្តិការថ្នាក់ស្រុកដែលគ្រប់ដណ្តប់ទាំងកិច្ចការរដ្ឋបាល ការគ្រប់គ្រងធនធានមនុស្ស និងការអនុវត្តគម្រោង ។ | $36,300 | $0 | $36,300 | Basket, EU-SPACE in kind |
| 2.5 | ការដាក់ឱ្យអនុវត្តនូវកិច្ចដំណើរការនានាសម្រាប់ការគ្រប់គ្រងធនធានមនុស្សដែលបានរៀបចំដោយអនុកម្មវិធីទី៣ ។ | $15,200 | $0 | $15,200 | Basket |
| 2.6 | ការអនុវត្តដំណើរការអភិវឌ្ឍស្ថាប័ន ។ | $46,800 | $0 | $46,800 | Basket |
| 2.7 | ការរៀបចំ និងការអនុវត្តសាកល្បងដំណើរការអធិការកិច្ច ឬការត្រួតពិនិត្យមើលពីលើនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចំនួន១២ ។ | $62,460 | $0 | $62,460 | Basket |
| 2.8 | ការពិនិត្យ កែតម្រូវឡើងវិញ និងអនុវត្តនូវយន្តការដោះស្រាយវិវាទនៅមូលដ្ឋានដែលជាផ្នែកមួយនៃការងាររបស់ក្រុមការងារគណនេយ្យភាពថ្នាក់រាជធានី ខេត្ត ។ | $9,350 | $0 | $9,350 | Basket |
| 2.9 | ការត្រួតពិនិត្យជាប្រចាំការគ្រប់គ្រង និងការបំពេញការងាររបស់ថ្នាក់ក្រោមជាតិ និងការផ្សព្វផ្សាយលទ្ធផលជាសាធារណៈ ។ | $45,980 | $0 | $45,980 | Basket |
| 2.10 | ការពង្រឹងការផ្តល់សេវាសង្គម និងការបំពេញមុខងាររបស់ គ.ក.ស.ក នៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ស្រុក និង គ.ក.ន.ក ឃុំ សង្កាត់ (UNFPA) ។ | $0 | $74,632 | $74,632 | UNFPA |
| 2.11 | ការពង្រឹងការផ្តល់សេវាសង្គមនៅថ្នាក់ក្រោមជាតិ (UNICEF) ។ | $0 | $74,000 | $74,000 | UNICEF |
| 2.12 | ការសាងសង់សាលាស្រុកចំនួន៤០ ។ | $0 | $3,500,000 | $3,500,000 | ADB |
| 2.13 | ការពង្រឹង និងគាំទ្រការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅក្រុង ស្រុក ខណ្ឌគោលដៅចំនួន៣៧ (OWSO) ។ | $0 | $1,066,928 | $1,066,928 | WB, RGC |
| 2.14 | ការគ្រប់គ្រងអនុកម្មវិធីទី២ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ។ | $309,974 | $25,260 | $335,234 | WB, Basket |
| | **សរុបថវិកា** | **$575,494** | **$4,740,820** | **$5,316,314** | |

# ជំពូកទី៣ ÷ ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
# (អនុកម្មវិធីទី៣)

## ៣.១. សេចក្តីផ្តើម

អនុកម្មវិធីទី៣ទទួលខុសត្រូវក្នុងការរៀបចំក្របខ័ណ្ឌ សម្រាប់ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់លទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រងបុគ្គលិករបស់ខ្លួន ស្របតាមបទបញ្ញត្តិច្បាស់លាស់ និងស្របតាមក្របខ័ណ្ឌរដ្ឋបាលទូទៅនៃមន្ត្រីរាជការស៊ីវិល ។ សមិទ្ធផលរំពឹងទុកនានារបស់អនុកម្មទី៣មានរៀបរាប់ដូចខាងក្រោម៖

**ប្រអប់ទី៤៖ សមិទ្ធផលរំពឹងទុកនៃផអ៣របស់អនុកម្មវិធីទី៣**

**សមិទ្ធផលរំពឹងទុក ÷**

- រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តការគ្រប់គ្រងធនធានមនុស្សរបស់ខ្លួនបានល្អប្រសើរជាងមុន (រួមបញ្ចូលទាំងការជ្រើសរើស និងការគ្រប់គ្រងបុគ្គលិកជាស្ត្រី [3.1-3.3] ។
- មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានមនុស្ស (ការជ្រើសរើស ការដាក់វិន័យ...) ត្រូវបាន ឬផ្ទេរឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ជាងនៅពេលដែលមុខងារទាំងនោះស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ថ្នាក់ជាតិ [3.1-3.3] ។
- ប្រសិទ្ធភាពនៃការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ ដោយសារតែមុខងារពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានមនុស្ស និងបុគ្គលិកត្រូវបានធ្វើប្រតិភូកម្មពីថ្នាក់ជាតិឱ្យថ្នាក់ក្រោមជាតិ [3.1-3.3] ។

*សម្គាល់ ៖ សមិទ្ធផលទាំងអស់គ្របដណ្តប់ក្នុងរយៈពេល ផអ៣ ទាំងមូល។*

## ៣.២. លទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៣

**លទ្ធផលរំពឹងទុក៣.១៖ ការរៀបចំបញ្ចប់លិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សតាមបែបវិមជ្ឈការ ។** ការងារនេះរួមមាន ការរៀបចំបញ្ចប់លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសម្រាប់អនុវត្តលក្ខន្តិកៈនេះ និងគោលនយោបាយស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**លទ្ធផលរំពឹងទុក៣.២៖ ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធទិន្នន័យសម្រាប់ការគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។** នៅក្នុងឆមាសទី១ឆ្នាំ២០១៤ ប្រព័ន្ធទិន្នន័យមួយនឹងត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ ។ ជាមួយគ្នានេះដែរ មន្ត្រីទទួលបន្ទុកការគ្រប់គ្រងបុគ្គលិកនៅថ្នាក់ក្រោមជាតិនឹងទទួលបានការបណ្តុះបណ្តាលអំពីប្រព័ន្ធទិន្នន័យសម្រាប់ការគ្រប់គ្រងធនធានមនុស្សនេះ ហើយទិន្នន័យពាក់ព័ន្ធនានានឹងត្រូវបានប្រមូលចងក្រងជាឯកសារ ។

**លទ្ធផលរំពឹងទុក៣.៣៖ ការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ។** ពាក់ព័ន្ធនឹងលទ្ធផលរំពឹងទុកនេះ អនុកម្មវិធីទី៣នឹងទទួលខុសត្រូវក្នុងរៀបចំនូវសៀវភៅណែនាំស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ អនុកម្មវិធីទី២នឹងទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីសៀវភៅណែនាំនេះដោយសហការជាមួយអនុកម្មវិធីទី៣ ។

**លទ្ធផលរំពឹងទុក៣.៤៖ ការគ្រប់គ្រងអនុកម្មវិធីទី៣ ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ។**

## ៣.៣ ថវិកានៃអនុកម្មវិធីទី៣

នៅឆ្នាំ២០១៤ ថវិកា ផ.ស.ថ របស់អនុកម្មវិធីទី៣មានដូចខាងក្រោម៖

**តារាងទី ៧: ថវិកាតាមលទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៣ (គិតជាដុល្លារ)**

| កូដ | លទ្ធផលរំពឹងទុក | កញ្ចប់រួម | ផ្សេងទៀត | សរុប | ប្រភព |
|---|---|---|---|---|---|
| 3.1 | ការរៀបចំបញ្ចប់លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងធនធាន និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ ។ | $35,000 | $0 | $35,000 | Basket, EU-SPACE in kind |
| 3.2 | ការរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវទិន្នន័យមូលដ្ឋានសម្រាប់ការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។ | $165,000 | $0 | $165,000 | Basket |
| 3.3 | ការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។ | $88,000 | $0 | $88,000 | Basket, EU-SPACE in kind |
| 3.4 | ការគ្រប់គ្រងអនុកម្មវិធីទី៣ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ។ | $68,820 | $0 | $68,820 | Basket |
| **សរុបរួម** | | **$356,820** | $0 | **$356,820** | |

# ជំពូកទី៤ ៖ ធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
# (អនុកម្មវិធីទី៤)

## ៤.១. សេចក្តីផ្តើម

អនុកម្មវិធីទី៤មានភារកិច្ចរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំនានាដែលចាំបាច់សម្រាប់ការផ្តល់ហិរញ្ញប្បទានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អនុកម្មវិធីនេះក៏ទទួលខុសត្រូវក្នុងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ការផ្តល់មូលនិធិតាមរយៈយន្តការនៃការផ្ទេរថវិកាពីថ្នាក់ជាតិ ការលើកកម្ពស់គណនេយ្យភាពផ្នែកហិរញ្ញវត្ថុ ព្រមទាំងការពង្រឹងតួនាទីក្នុងការត្រួតពិនិត្យមើលពីលើផ្នែកហិរញ្ញវត្ថុ និងមុខងារគាំទ្រនានា។ សមិទ្ធផលរំពឹងទុកនានារបស់អនុកម្មវិធីទី៤មានរៀបរាប់ដូចខាងក្រោម៖

**ប្រអប់ទី៥៖ សមិទ្ធផលរំពឹងទុកនៃ៥អត្ថរបស់អនុកម្មវិធីទី៤**

**សមិទ្ធផលរំពឹងទុក ៖**

- បុគ្គលិកនៅថ្នាក់ក្រោមជាតិដែលទទួលបន្ទុកការគ្រប់គ្រងហិរញ្ញវត្ថុមានការយល់ដឹង និងចំណេះដឹងកាន់តែច្រើនពាក់ព័ន្ធនឹងផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ [4.9, 4.10]។
- បុគ្គលិកនៅថ្នាក់ក្រោមជាតិដែលទទួលបន្ទុកការគ្រប់គ្រងហិរញ្ញវត្ថុអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបានកាន់តែល្អប្រសើរជាងមុន [4.9, 4.10]។
- រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងផ្នែកហិរញ្ញវត្ថុបានល្អប្រសើរជាងមុន [4.10]
- រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រងប្រភពធនធានហិរញ្ញវត្ថុបានកាន់តែល្អជាងមុន [4.9, 4.10]។
- រដ្ឋបាលថ្នាក់ក្រោមជាតិប្រមូលចំណូលនៅមូលដ្ឋានបានកាន់តែច្រើន និងកាន់តែមានការផ្តួចផ្តើមក្នុងវិធីសាស្ត្រនៃការប្រមូលចំណូលមូលដ្ឋានរបស់ខ្លួន [4.1, 4.3]។
- រដ្ឋបាលថ្នាក់ក្រោមជាតិអភិបាលការងារហិរញ្ញវត្ថុរបស់ខ្លួនបានប្រសើរជាងមុន (កាន់តែមានតម្លាភាព គណនេយ្យភាព និងកាត់បន្ថយអំពើពុករលួយ) ហើយប្រជាពលរដ្ឋ និងតំណាងរបស់ខ្លួនមានការយល់ដឹងអំពីថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែច្រើនឡើង [4.9, 4.10]។
- តម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋត្រូវបានឆ្លុះបញ្ចាំងកាន់តែល្អប្រសើរឡើងនៅក្នុងផែនការថវិកា និងការអនុវត្តថវិការបស់ក្រុមប្រឹក្សា (រួមទាំងក្រុមជនងាយរងគ្រោះ) [4.11]។
- ក្រុមជនងាយរងគ្រោះ (រួមទាំងស្ត្រី យុវជន ជនជាតិដើមភាគតិច...) និងការបញ្ជ្រាបយេនឌ័រត្រូវបានគាំទ្រ លើកកម្ពស់ និងការពារបានល្អប្រសើរជាងមុន តាមរយៈការប្រើប្រាស់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ [4.1, 4.11]។
- រដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវាជូនប្រជាពលរដ្ឋបានល្អជាងមុន (ដោយសារសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុមានការកើនឡើង និងមានមូលនិធិច្រើនជាងមុន) [លទ្ធផលរំពឹងទុកទាំងអស់]។
- ធនធានហិរញ្ញវត្ថុបន្ថែមដែលត្រូវបានផ្ទេរឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ បានលើកកម្ពស់ការផ្តល់សេវាបានល្អប្រសើរជាងការផ្តល់ដោយថ្នាក់ជាតិ (ឧទាហរណ៍ មានអត្រានៃការទទួលបានពីការវិនិយោគ ឬនាំឱ្យមានការកើនឡើងនូវតម្លៃរូបិយវត្ថុខ្ពស់ជាង) [លទ្ធផលរំពឹងទុកទាំងអស់]។

**សម្គាល់ ៖** លទ្ធផលរំពឹងទុកនានាដែលរួមចំណែកដោយផ្ទាល់ដល់សមិទ្ធផលនីមួយៗដូចមានបញ្ជាក់ក្នុងវង់ក្រចក។ លទ្ធផលរំពឹងទុកមួយអាចរួមចំណែកដល់សមិទ្ធផលច្រើន។ សមិទ្ធផលទាំងអស់គ្របដណ្តប់ក្នុងរយៈពេលផអពាទាំងមូល។

## ៤.២. លទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៤

**លទ្ធផលរំពឹងទុក៤.១៖ ការរៀបចំបញ្ចប់គោលនយោបាយស្តីពីវិមជ្ឈការសារពើពន្ធ។** លទ្ធផលរំពឹងទុកនេះបង្ហាញអំពីទស្សនៈរបស់រាជរដ្ឋាភិបាលស្តីពីការផ្ទេរសារពើពន្ធ និងចំណូលផ្ទាល់ ការព្យាករណ៍អំពីកម្រិតនៃធនធានសម្រាប់ប្រភេទរដ្ឋបាលនីមួយៗ និងតាមប្រភពធនធានហិរញ្ញវត្ថុសម្រាប់រយៈពេលមធ្យម។ ទស្សនៈនេះ និងចំណុចដៅ គឺជាផ្នែកមួយដ៏មានសារសំខាន់សម្រាប់ការរៀបចំផែនការអនុវត្តដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ។

**លទ្ធផលរំពឹងទុក៤.២៖ ការរៀបចំបង្កើត និងការដាក់ឱ្យអនុវត្តសាកល្បងនូវឧបករណ៍វិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) និងការធានានូវប្រភពធនធានសម្រាប់ឆ្នាំ២០១៥ (មានគម្រោងថវិកាប្រមាណ៣០លានដុល្លារ)។** ក្នុងឆ្នាំ២០១៤ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំនានានឹងត្រូវបានរៀបចំបញ្ចប់។ ជាមួយគ្នានេះដែរ ការផ្តល់មូលនិធិសម្រាប់ការអនុវត្តឧបករណ៍វិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានឯកភាពនិងគាំទ្រ ហើយឧបករណ៍នេះនឹងត្រូវបានអនុវត្តសាកល្បង។

**លទ្ធផលរំពឹងទុក៤.៣៖ ឯកសារគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បង សម្រាប់ការអនុវត្តពេញលេញនៅឆ្នាំ២០១៥។** ឯកសារគោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធនានានឹងត្រូវបានរៀបចំ ដោយកំណត់យ៉ាងច្បាស់នូវចំណុចដៅដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រមូលចំណូលពីប្រភពចំណូលផ្ទាល់របស់ខ្លួន (ដើម្បីលើកកម្ពស់ស្វ័យភាព និងគណនេយ្យភាព)។ កម្រៃក្រៅប្រព័ន្ធនឹងត្រូវបានរៀបចំឱ្យមានជាទម្រង់ផ្លូវការ ហើយការសាកល្បងនឹងត្រូវបានរៀបចំ និងអនុវត្តនៅតាមរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ។ ក្នុងការអនុវត្តការសាកល្បងនេះ ចំណូលផ្ទាល់នឹងត្រូវបានប្រមូល និងគ្រប់គ្រង។ នៅចុងឆ្នាំ២០១៤ ការអនុវត្តសាកល្បងនឹងត្រូវបានវាយតម្លៃក្នុងបំណងពង្រីកការអនុវត្តនៅក្នុងឆ្នាំ២០១៥។

**លទ្ធផលរំពឹងទុក៤.៤៖ ការរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងនូវយន្តការផ្តល់ហិរញ្ញប្បទានមានភ្ជាប់លក្ខខណ្ឌ មានគោលបំណងជាក់លាក់ និងវិធីបែបផែនការនៃការផ្តល់ហិរញ្ញប្បទានតាមលក្ខណៈកិច្ចសន្យាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។** យន្តការនេះគាំទ្រដល់ការអនុវត្តមុខងារជាអាណត្តិទូទៅ និងការអនុវត្តនូវការផ្ទេរមុខងារដែលត្រូវបានផ្ទេរឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិនាពេលអនាគត។ ចំណុចទាំងពីរនេះនឹងផ្តល់នូវយន្តការមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីទទួលនូវការផ្ទេរនានាពីថ្នាក់ជាតិ (ឧទាហរណ៍ ប្រសិនបើមុខងារនៃការផ្សព្វផ្សាយកសិកម្មត្រូវបានផ្ទេរឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ) ធ្វើការផ្ទេរឱ្យទៅភ្នាក់ងារពាក់ព័ន្ធនានារបស់ថ្នាក់ជាតិ (ឧទាហរណ៍ ដើម្បីទិញសៀវភៅសម្រាប់សាលា) សម្រាប់ថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិណាមួយ ធ្វើការផ្ទេរធនធានឱ្យទៅរដ្ឋបាលថ្នាក់ណាមួយផ្សេងទៀត ឬក៏សម្រាប់ដៃគូអភិវឌ្ឍន៍ក្នុងការចូលរួមមូលនិធិគាំទ្រសម្រាប់គោលដៅជាក់លាក់។ យន្តការទាំងនេះនឹងត្រូវធ្វើការសាកល្បងដែលផ្នែកមួយនៃការអនុវត្តសាកល្បងនូវមុខងារជាអណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (សូមមើលលទ្ធផលរំពឹងទុកទី 1.3)។

**លទ្ធផលរំពឹងទុក៤.៥៖ ការរៀបចំប្រព័ន្ធរៀបចំវិភាជន៍ថវិការាជធានី ខេត្តផ្អែកលើរូបមន្ត សម្រាប់ការអនុវត្តក្នុងនៅឆ្នាំ២០១៦។** កិច្ចការនេះរាប់បញ្ចូលទាំងការរៀបចំនូវអនុក្រឹត្យ ប្រកាស ឬបទបញ្ញត្តិចាំបាច់នានា។

**លទ្ធផលរំពឹងទុក៤.៦៖ ការវិភាជន៍ និងអនុវត្តមូលនិធិឃុំ សង្កាត់ ក្នុងឃុំ សង្កាត់ចំនួន១.៦៣៣។** មូលនិធិឃុំ សង្កាត់មានអត្រាស្មើនឹង២,៨%នៃថវិកាចំណូលចរន្តសរុបរបស់ជាតិ ហើយសម្រាប់ឆ្នាំ២០១៤ មូលនិធិនេះមានចំនួន៥៩,០៧លានដុល្លារអាមេរិកដែលត្រូវបានវិភាជសម្រាប់ឃុំ សង្កាត់ទាំង១.៦៣៣។

**លទ្ធផលរំពឹងទុក៩.៧៖ ការវិភាជន៍ និងអនុវត្តមូលនិធិក្រុង ស្រុក ក្នុងក្រុង ស្រុកចំនួន១៨៥។** មូលនិធិក្រុង ស្រុកមានអត្រាស្មើនឹង០,៨០% នៃថវិកាចំណូលចរន្តសរុបរបស់ជាតិ។ សម្រាប់ឆ្នាំ២០១៤ មូលនិធិក្រុង ស្រុកមានចំនួន២១,០៥លានដុល្លារអាមេរិកដែលក្នុងនោះថវិការបស់រាជរដ្ឋាភិបាលមានចំនួន១៧,០៥លានដុល្លារអាមេរិក និងថវិកាចូលរួមបដិភាគរបស់ Sida មានចំនួន៤លានដុល្លារអាមេរិក។

**លទ្ធផលរំពឹងទុក៩.៨៖ ការវិភាជន៍ និងការអនុវត្តថវិការាជធានី ខេត្តនៅក្នុង២៤រាជធានី ខេត្ត។** នៅក្នុងឆ្នាំ២០១៤នេះ ថវិការាជធានី ខេត្តមានចំនួន១៥៨,២៣លានដុល្លារអាមេរិក។

**លទ្ធផលរំពឹងទុក៩.៩៖ ការពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តសេចក្តីណែនាំនានាស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក។** លទ្ធផលរំពឹងទុកនេះរួមបញ្ចូលទាំងការបណ្តុះបណ្តាលផ្នែកថវិកា ការគ្រប់គ្រងហិរញ្ញវត្ថុ និងនីតិវិធីលទ្ធកម្ម។

**លទ្ធផលរំពឹងទុក៩.១០៖ ការពង្រឹងសមត្ថភាពស្តីពីការត្រួតពិនិត្យមើលពីលើ និងការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក។** កិច្ចការនេះរួមបញ្ចូលទាំងការបណ្តុះបណ្តាលអំពីកិច្ចការគណនីនានា និងការបិទបញ្ជីគណនី ការបណ្តុះបណ្តាលអំពីការគ្រប់គ្រងថវិកា និងការគ្រប់គ្រងហិរញ្ញកិច្ចដល់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន និងការបណ្តុះបណ្តាលអំពីសវនកម្មដល់អាជ្ញាធរសវនកម្មជាតិ។

**លទ្ធផលរំពឹងទុក៩.១១៖ ការរៀបចំ និងការផ្សព្វផ្សាយនូវគោលនយោបាយ និងនីតិវិធីសម្រាប់ការរៀបចំថវិកាដែលឆ្លើយតបទៅនឹងយេនឌ័រ និងការដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៦។**

**លទ្ធផលរំពឹងទុក៩.១២៖ ការគ្រប់គ្រងអនុកម្មវិធីទី៤ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។**

## ៤.៣. ថវិកានៃអនុកម្មវិធីទី៤

**តារាងទី៤៖ ថវិកាតាមលទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៤ (គិតជាដុល្លារ)**

| កូដ | លទ្ធផលរំពឹងទុក | កញ្ចប់រួម | រដ្ឋាភិបាល | ផ្សេងទៀត | សរុប | ប្រភព |
|---|---|---|---|---|---|---|
| 4.1 | ការរៀបចំបញ្ចប់គោលនយោបាយស្តីពីវិមជ្ឈការហិរញ្ញវត្ថុ។ | $0 | $0 | $0 | $0 | Basket |
| 4.2 | ការរៀបចំ និងការដាក់ឱ្យអនុវត្តសាកល្បងនូវឧបករណ៍វិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) និងការធានានូវប្រភពធនធានសម្រាប់ការអនុវត្តឆ្នាំ២០១៥។ | $0 | $0 | $114,076 | $114,076 | ADB |
| 4.3 | ការរៀបចំ និងអនុវត្តសាកល្បង គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសម្រាប់ការអនុវត្តពេញលេញក្នុងឆ្នាំ២០១៥។ | $0 | $0 | $76,612 | $76,612 | ADB |
| 4.4 | ការរៀបចំបង្កើត និងដាក់ឱ្យសាកល្បង យន្តការផ្តល់ហិរញ្ញប្បទានមានភ្ជាប់លក្ខខណ្ឌដែលមានគោលបំណងជាក់លាក់សម្រាប់រដ្ឋបាលថ្នាក់ | $0 | $0 | $66,276 | $66,276 | ADB |

| កូដ | លទ្ធផលរំពឹងទុក | កញ្ចប់រួម | រដ្ឋាភិបាល | ផ្សេងទៀត | សរុប | ប្រភព |
|---|---|---|---|---|---|---|
| | ក្រោមជាតិ ។ | | | | | |
| 4.5 | ការរៀបចំប្រព័ន្ធវិភាជន៍ថវិការាជធានី ខេត្ត ផ្អែកលើរូបមន្ត សម្រាប់ការអនុវត្តក្នុងឆ្នាំ ២០១៦ ។ | $0 | $0 | $0 | $0 | Basket |
| 4.6 | ការវិភាជន៍ និងការអនុវត្តមូលនិធិឃុំ សង្កាត់ក្នុង ឃុំ សង្កាត់ចំនួន១.៦៣៣ ។ | $0 | $58,584,198 | $481,284 | $59,065,482 | RGC, UNICEF |
| 4.7 | ការវិភាជន៍ និងការអនុវត្តមូលនិធិក្រុង ស្រុក ក្នុងក្រុង ស្រុកចំនួន១៨៥ ។ | $0 | $17,047,901 | $4,000,000 | $21,047,901 | RGC, Sida |
| 4.8 | ការវិភាជន៍ និងការអនុវត្តថវិការាជធានី ខេត្ត ក្នុងរាជធានី និងខេត្តចំនួន២៤ ។ | $0 | $158,231,605 | $0 | $158,231,605 | RGC |
| 4.9 | ការពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោម ជាតិក្នុងការអនុវត្តសេចក្តីណែនាំស្តីពីការគ្រប់ គ្រងហិរញ្ញវត្ថុក្រុង ស្រុក ។ | $42,900 | $0 | $152,966 | $195,866 | Basket, ADB |
| 4.10 | ការពង្រឹងសមត្ថភាពស្តីពីការត្រួតពិនិត្យមើល ពីលើផ្នែកហិរញ្ញវត្ថុ ។ | $0 | $0 | $112,830 | $112,830 | ADB |
| 4.11 | ការរៀបចំ និងការផ្សព្វផ្សាយនូវគោល នយោបាយ និងនីតិវិធីសម្រាប់ការរៀបចំថវិកា ដែលឆ្លើយតបទៅនឹងយេនឌ័រ និងការដាក់ឱ្យ អនុវត្តនៅឆ្នាំ២០១៦ ។ | $51,177 | $0 | $0 | $51,177 | Basket |
| 4.12 | ការគ្រប់គ្រងអនុកម្មវិធីទី៤ប្រកបដោយ ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ។ | $81,280 | $0 | $0 | $81,280 | Basket |
| សរុបថវិកា | | **$175,357** | **$233,863,704** | **$5,004,044** | **$239,043,105** | |

# ជំពូកទី៥ ៖ ប្រព័ន្ធកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ (អនុកម្មវិធីទី៥)

## ៥.១. សេចក្តីផ្តើម

គោលបំណងរបស់អនុកម្មវិធីទី៥ គឺដើម្បីអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការអភិវឌ្ឍជាយុទ្ធសាស្ត្រ និងកម្មវិធីវិនិយោគរបស់ខ្លួន។ សមិទ្ធផលរំពឹងទុកនានារបស់អនុកម្មវិធីទី៥មានរៀបរាប់ដូចខាងក្រោម៖

**ប្រអប់ទី៦៖ សមិទ្ធផលរំពឹងទុករបស់ផអ៣នៃអនុកម្មវិធីទី៥**

**សមិទ្ធផលរំពឹងទុក ៖**

- បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិមានចំណេះដឹង និងសមត្ថភាពកើនឡើងអំពីការកសាងផែនការ [5.1]។
- ផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែល្អប្រសើរ ការរៀបចំផែនការកាន់តែមានតម្លាភាព និងកាន់តែមានការចូលរួមពីប្រជាពលរដ្ឋច្រើនជាងមុន។ ជាមួយគ្នានេះដែរ ផែនការនេះកាន់តែមានលក្ខណៈងាយយល់ដោយប្រជាពលរដ្ឋ និងតំណាងរបស់ខ្លួន [5.1, 5.2]។
- អាទិភាពនានារបស់ប្រជាពលរដ្ឋ (រួមទាំងក្រុមជនងាយរងគ្រោះនានា) ត្រូវបានឆ្លុះបញ្ចាំងបានល្អប្រសើរជាងមុននៅក្នុងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ពាក់ព័ន្ធលទ្ធផលរំពឹងទុកទាំងអស់ដោយផ្ទាល់)។

**សម្គាល់ ៖** លទ្ធផលរំពឹងទុកនានាដែលរួមចំណែកដោយផ្ទាល់ដល់សមិទ្ធផលនីមួយៗដូចមានបញ្ជាក់ក្នុងវង់ក្រចក។ លទ្ធផលរំពឹងទុកមួយអាចរួមចំណែកដល់សមិទ្ធផលច្រើន។ សមិទ្ធផលទាំងអស់គ្របដណ្តប់ក្នុងរយៈពេលផអ៣ទាំងមូល។

## ៥.២. លទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៥

**លទ្ធផលរំពឹងទុក៥.១៖ ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធកសាងផែនការ និងថវិកាសម្រាប់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ។** សេចក្តីណែនាំស្តីពីការកសាងផែនការនិងថវិការបស់រដ្ឋបាលរាជធានី ខេត្ត និងរបស់ក្រុង ស្រុក ខណ្ឌនឹងត្រូវបានរៀបចំ អនុវត្តសាកល្បង និងអនុម័ត។ កិច្ចដំណើរការនៃការរៀបចំសេចក្តីណែនាំនេះរួមមាន៖

- ការពិនិត្យ និងអនុម័តលើសេចក្តីព្រាងគោលនយោបាយស្តីពីប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយ គ.ជ.អ.ប ។
- ការអនុវត្តការសិក្សា ដើម្បីធានាឱ្យមាននូវភាពប្រទាក់ក្រឡាគ្នារវាងកិច្ចដំណើរការកសាងផែនការ និងកិច្ចដំណើរការនៃការរៀបចំថវិកាដែលក្នុងនោះរួមមាន ការពិនិត្យឡើងវិញនូវសេចក្តីណែនាំនានាផ្នែកកសាងផែនការ និងរៀបចំថវិកាដែលមានបច្ចុប្បន្ននៅថ្នាក់ក្រោមជាតិ ការរៀបចំប្រតិទិនដែលបន្សុីរវាងការកសាងផែនការ និងការរៀបចំថវិកា និងការរៀបចំពិនិត្យឡើងវិញនូវសេចក្តីណែនាំស្តីពីការកសាងផែនការ និងការរៀបចំថវិកាសម្រាប់រដ្ឋបាលប្រភេទផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការគាំទ្រផ្នែកទីប្រឹក្សាសម្រាប់ការសិក្សានេះនឹងត្រូវបានគាំទ្រដោយអនុកម្មវិធីទី១។
- ការរៀបចំបញ្ចប់ និងអនុម័តនូវរាល់សេចក្តីណែនាំចាំបាច់នានា។
- ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីសេចក្តីណែនាំនានាដែលបានកែសម្រួល និងអនុម័ត។

• ការរៀបចំសេចក្តីព្រាងបឋមស្តីពីប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីពិនិត្យមើលការអនុវត្តផែនការ ។

**លទ្ធផលរំពឹងទុក ៥.២៖ ការពិនិត្យ និងការកែសម្រួលឡើងវិញនូវទិន្នន័យមូលដ្ឋានឃុំ សង្កាត់ (CDB) ប្រព័ន្ធទិន្នន័យផែនការអភិវឌ្ឍឃុំ សង្កាត់ (CDPD) ។** ទិន្នន័យនានាសម្រាប់ការកសាងផែនការនៅរដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានប្រមូល និងបញ្ចូលក្នុងប្រព័ន្ធទិន្នន័យ CDB និង CDPD ហើយការបណ្តុះបណ្តាលអំពីទិន្នន័យមូលដ្ឋានឃុំ សង្កាត់ ដោយប្រើប្រាស់តារាងពិន្ទុគោលដៅអភិវឌ្ឍន៍ និងកិច្ចដំណើរការនានានៃការប្រមូលទិន្នន័យពាក់ព័ន្ធផ្សេងទៀតក៏នឹងត្រូវបានរៀបចំឡើង ។

**លទ្ធផលរំពឹងទុក ៥.៣៖ ការគ្រប់គ្រងអនុកម្មវិធីទី៥ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ។**

## ៥.៣. ថវិការបស់អនុកម្មវិធីទី៥

ផែនការសកម្មភាព និងថវិការបស់អនុកម្មវិធីទី៥សម្រាប់ថ្នាក់ជាតិមានដូចខាងក្រោម ។

**តារាងទី៩៖ ថវិកាតាមលទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៥ (គិតជាដុល្លារ)**

| កូដ | លទ្ធផលរំពឹងទុក | កញ្ចប់រួម | ផ្សេងទៀត | សរុប | ប្រភព |
|---|---|---|---|---|---|
| 5.1 | ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធកសាងផែនការ និងថវិកាសម្រាប់រដ្ឋបាលថ្នាក់រាជធានី ខេត្ត និងរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ។ | $0 | $114,000 | $114,000 | UNICEF, PILAC2 |
| 5.2 | ការពិនិត្យ និងការកែសម្រួលទិន្នន័យមូលដ្ឋានឃុំ សង្កាត់ (CDB) និងប្រព័ន្ធទិន្នន័យផែនការអភិវឌ្ឍឃុំ សង្កាត់ (CDPD) ។ | $20,490 | $25,000 | $45,490 | UNICEF, UNDP, Basket |
| 5.3 | ការគ្រប់គ្រងអនុកម្មវិធីទី៥ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ។ | $25,000 | $0 | $25,000 | Basket |
| | **សរុបថវិកា** | **$45,490** | **$139,000** | **$184,490** | |

# ជំពូកទី៦ ÷ សមត្ថភាពរបស់សមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (អនុកម្មវិធីទី៦)

## ៦.១. សេចក្តីផ្តើម

អនុកម្មវិធីទី៦បរិយាយអំពីការបង្កើត ការចុះបញ្ជីតាមច្បាប់ និងការអភិវឌ្ឍសមត្ថភាពដល់សមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន២ដែលរួមមាន៖ (១) សមាគមក្រុមប្រឹក្សាថ្នាក់តំបន់ដែលតំណាងឱ្យក្រុមប្រឹក្សារាជធានី និងក្រុមប្រឹក្សាខេត្ត និង (២) សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានដែលតំណាងឱ្យក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក៏ដូចជាអគ្គលេខាធិការដ្ឋានរបស់សម្ព័ន្ធភាពជាតិ។ សមិទ្ធផលរំពឹងទុកនានារបស់អនុកម្មវិធីទី៦មានរៀបរាប់ដូចខាងក្រោម ៖

**ប្រអប់ទី៧៖ សមិទ្ធផលរំពឹងទុកនៃផអសា៣របស់អនុកម្មវិធីទី៦**

**សមិទ្ធផលរំពឹងទុក ÷**

- ផលប្រយោជន៍នានារបស់ក្រុមប្រឹក្សាត្រូវបានលើកកម្ពស់ និងការពារកាន់តែប្រសើរឡើងតាមរយៈសមាគមក្រុមប្រឹក្សា [6.1, 6.3]។
- សមាគមក្រុមប្រឹក្សានានាផ្តល់សេវាកាន់តែមានគុណភាព និងស្របតាមតម្រូវការរបស់សមាជិកខ្លួន [6.1, 6.2]។
- និរន្តរភាពហិរញ្ញវត្ថុរបស់សមាគមក្រុមប្រឹក្សាមានភាពប្រសើរឡើង [6.2]។

**សម្គាល់ ៖** លទ្ធផលរំពឹងទុកនានាដែលរួមចំណែកដោយផ្ទាល់ដល់សមិទ្ធផលនីមួយៗដូចមានបញ្ជាក់ក្នុងវង់ក្រចក។ លទ្ធផលរំពឹងទុកមួយអាចរួមចំណែកដល់សមិទ្ធផលច្រើន។ សមិទ្ធផលទាំងអស់គ្របដណ្តប់ក្នុងរយៈពេលផអព៣ទាំងមូល។

## ៦.២. លទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៦

ខាងក្រោមបង្ហាញពីលទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៦ដែលត្រូវសម្រេចក្នុងឆ្នាំ២០១៤។

**លទ្ធផលរំពឹងទុក៦.១៖ ការបង្កើត និងការចុះបញ្ជីតាមច្បាប់នៃសមាគមក្រុមប្រឹក្សារាជធានី ខេត្ត និងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។** នៅឆ្នាំ២០១៣ សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់បានបង្កើតនៅក្នុងរាជធានី ខេត្តចំនួន១១។ នៅត្រីមាសទី១នៃឆ្នាំ២០១៤ សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំសង្កាត់ដែលនៅសល់ក្នុង ខេត្តចំនួន ១៣ នឹងត្រូវបានបង្កើត និងរៀបចំជាសម្ព័ន្ធភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ នៅចុងឆ្នាំ២០១៤ សមាគមក្រុមប្រឹក្សារាជធានី ខេត្ត និងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នឹងដំណើរការរបស់ខ្លួនយ៉ាងពេញលេញ។

**លទ្ធផលរំពឹងទុក៦.២៖ ការពង្រឹងសមត្ថភាពរបស់ស្ថាប័ននៃសមាគមក្រុមប្រឹក្សា និងសម្ព័ន្ធភាពជាតិ។**

- កំណត់ និងពង្រឹងមុខងារផ្នែកច្បាប់និងការតស៊ូមតិ (ឧទាហរណ៍ មុខងារក្នុងការផ្តល់សេវា) និងសមត្ថភាព
- រៀបចំឡើងវិញនូវរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ដើម្បីគាំទ្រសមាគមទាំង២ រួមបញ្ចូលទាំងការរៀបចំបញ្ចប់នូវលក្ខខណ្ឌការងារនានា
- រៀបចំបញ្ចប់លក្ខន្តិកៈថ្មី និងការរៀបចំផែនការយុទ្ធសាស្ត្រថ្មីមួយសម្រាប់សម្ព័ន្ធភាពជាតិ

**លទ្ធផលរំពឹងទុក៦.៣៖ យុទ្ធសាស្ត្រស្តីពីគាំទ្រហិរញ្ញវត្ថុដល់សមាគមទាំង២ ត្រូវបានរៀបចំ ឯកភាព និងរួចរាល់សម្រាប់ការអនុវត្តនៅឆ្នាំ២០១៥។**

**លទ្ធផលរំពឹងទុក៦.៤៖ ការគ្រប់គ្រងអនុកម្មវិធីទី៦ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។**

## ៦.៣. ថវិកានៃអនុកម្មវិធីទី៦

**តារាងទី១០៖ ថវិកាតាមលទ្ធផលរំពឹងទុករបស់អនុកម្មវិធីទី៦ (គិតជាដុល្លារ)**

| កូដ | លទ្ធផលរំពឹងទុក | កញ្ចប់រួម | ផ្សេងទៀត | សរុប | ប្រភព |
|---|---|---|---|---|---|
| 6.1 | ការបង្កើត និងការចុះបញ្ជីតាមច្បាប់នៃសមាគមក្រុមប្រឹក្សារាជធានី ខេត្ត និងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ | $17,300 | $180,155 | $197,455 | Basket, ACES |
| 6.2 | ការពង្រឹងសមត្ថភាពស្ថាប័នរបស់សមាគមក្រុមប្រឹក្សា និងសម្ព័ន្ធភាពជាតិ។ | $11,700 | $209,527 | $221,227 | Basket, ACES |
| 6.3 | យុទ្ធសាស្ត្រស្តីពីការគាំទ្រហិរញ្ញវត្ថុដល់សមាគមទាំង២ត្រូវបានរៀបចំ ឯកភាព និងរួចរាល់សម្រាប់ការអនុវត្តនៅឆ្នាំ២០១៥។ | $8,200 | $0 | $8,200 | Basket |
| 6.4 | ការគ្រប់គ្រងអនុកម្មវិធីទី៦ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ | $83,320 | $0 | $83,320 | Basket |
| | **សរុបថវិកា** | **$120,520** | **$389,682** | **$510,202** | |

# ជំពូកទី៧ ÷ លទ្ធផលរំពឹងទុករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

## ៧.១. សេចក្តីផ្តើម

ជំពូកនេះសង្ខេបអំពីថវិកាសម្រាប់លទ្ធផលរំពឹងទុកនានាដែលត្រូវអនុវត្តនៅថ្នាក់ក្រោមជាតិ តាមរយៈការវិភាជន៍ពីមូលនិធិកញ្ចប់រួមដែលមានគោលដៅប្រើប្រាស់ជាក់លាក់ និងពីគម្រោងរបស់ដៃគូអភិវឌ្ឍន៍ជាក់លាក់នានា។ លទ្ធផលរំពឹងទុកទាំងនេះពាក់ព័ន្ធជាមួយអនុកម្មវិធីនានានៃផអ៣ (អនុកម្មវិធី១ ទី២ ទី៤ និងទី៥) ប៉ុន្តែត្រូវបានរៀបចំ និងដាក់ក្នុងជំពូកមួយដោយឡែកដើម្បីបង្ហាញឱ្យឃើញពីភាពចាំបាច់ និងមានសារសំខាន់នៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តផអ៣។ ក្នុងពេលរៀបចំបញ្ចប់សេចក្តីសម្រេចរួមរវាង គ.ជ.អ.ប ជាមួយស្ថាប័នអនុវត្តន៍នានា អាចមានលទ្ធផលរំពឹងទុកមួយចំនួនទៀតត្រូវបានកំណត់បន្ថែម (ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពបណ្តុះបណ្តាល) និងដាក់បញ្ចូលក្នុង ផ.ស.ថ របស់រាជធានី ខេត្តនីមួយៗ។

## ៧.២. លទ្ធផលរំពឹងទុក និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

លទ្ធផលរំពឹងទុក និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០១៤មានដូចខាងក្រោម ៖

**តារាងទី១១ ៖ លទ្ធផលរំពឹងទុក និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

| ល.រ | ប្រភេទរដ្ឋបាល | សរុប | ប្រភព | អនុកម្មវិធី |
|---|---|---|---|---|
| **ក.** | **រដ្ឋបាលរាជធានី ខេត្ត** | **$4,577,725** | | |
| 1 | ការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពជាក់លាក់របស់រដ្ឋបាលរាជធានី ខេត្តទាំង២៤ | $120,000 | Basket | SP1 |
| 2 | ការរៀបចំវគ្គបណ្តុះបណ្តាលអំពីដំណើរការកសាងផែនការនិងការរៀបចំកម្មវិធីវិនិយោគថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយមានកិច្ចសហការជាមួយក្រសួងផែនការ និងក្រសួងមហាផ្ទៃ | $77,000 | Basket | SP1 |
| 3 | ការផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការអនុវត្តផែនការយុទ្ធសាស្រ្តគណនេយ្យភាពសង្គម | $80,000 | Basket | SP1 |
| 4 | ការគាំទ្រការបញ្ជ្រាបយេនឌ័ររបស់ផអ៣ នៅថ្នាក់ក្រោមជាតិ | $155,200 | Basket | SP1 |
| 5 | ការលើកកម្ពស់ការអនុវត្តមុខងាររបស់ គ.ក.ស.ក របស់រាជធានី ខេត្តទាំង២៤ | $27,500 | Basket, UNICEF & UNFPA | SP1, SP2 |
| 6 | ការតាមដាន និងការគាំទ្របច្ចេកទេសអំពីការផ្តល់សេវាសង្គមដល់ឃុំចំនួន១០១ | $31,000 | UNICEF | SP1 |
| 7 | ការរៀបចំសិក្ខាសាលាស្តីអំពីការកសាងផែនការត្រៀមបម្រុង និងការឆ្លើយតបចំពោះគ្រោះអាសន្ននៅក្នុងខេត្តគោលដៅទាំងចំនួន៩ | $9,000 | UNICEF | SP1 |
| 8 | រៀបចំការប្រជុំប្រចាំត្រីមាសរវាងមន្ត្រីបង្គោលទទួលបន្ទុកស្ត្រីនិងកុមារឃុំសង្កាត់ និងការតាមដានដើម្បីធានាកិច្ចដំណើរការមត្តេយ្យសហគមន៍ចំនួន១.១១៥ នៅក្នុងខេត្តចំនួន១២ | $17,750 | UNICEF | SP1 |
| 9 | ការអនុវត្តទម្រង់រៀបចំរបាយការណ៍របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | $6,000 | Basket | SP2 |
| 10 | ការផ្សព្វផ្សាយអនុក្រឹត្យ និងសេចក្តីណែនាំស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ច មន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ | $6,000 | Basket | SP2 |
| 11 | ការអនុវត្តប្រព័ន្ធវាយតម្លៃការបំពេញភារៈកិច្ចរបស់បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | $6,000 | Basket | SP2 |

| ល.រ | ប្រភេទរដ្ឋបាល | សរុប | ប្រភព | អនុកម្មវិធី |
|---|---|---|---|---|
| 12 | ការបណ្តុះបណ្តាលសៀវភៅណែនាំស្តីពីការអនុវត្តតួនាទី និងភារកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | $73,180 | Basket | SP2 |
| 13 | ការរៀបចំ និងការអនុវត្តនូវផែនការអភិវឌ្ឍស្ថាប័នសម្រាប់ថ្នាក់ក្រោមជាតិ | $6,000 | Basket | SP2 |
| 14 | ការពង្រឹងកិច្ចដំណើរការកសាងផែនការ និងថវិកានៅថ្នាក់ក្រោមជាតិ | $23,500 | UNICEF | SP2 |
| 15 | ការលើកកម្ពស់ការចុះបញ្ជីអត្រានុកូលដ្ឋាននៅក្នុងខេត្តគោលដៅចំនួន៩ | $27,000 | UNICEF | SP2 |
| 16 | ការពង្រឹងការផ្តល់សេវាសង្គមនៅថ្នាក់ឃុំ សង្កាត់ | $130,450 | UNICEF | SP2 |
| 17 | ការផ្តួចផ្តើមគំនិតថ្នាក់តំបន់ដោយផ្តោតជាពិសេសលើសមាហរណកម្មរវាងការថែទាំកុមារតូចជាមួយសេវាអភិវឌ្ឍនានា | $15,000 | UNICEF | SP2 |
| 18 | ការរៀបចំប្រជុំប្រចាំត្រីមាសនិងឆមាស និងការធ្វើសវនកម្មប្រចាំឆ្នាំ | $7,996 | UNFPA | SP2 |
| 19 | ការតាមដាន ការគាំទ្របច្ចេកទេស និងប្រតិបត្តិការសម្រាប់ការងារសេវាសង្គម | $5,040 | UNFPA | SP2 |
| 20 | ការកសាងសមត្ថភាពស្តីអំពីការគ្រប់គ្រងហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្មក្រុង ស្រុក ខណ្ឌ | $126,609 | Basket | SP4 |
| 21 | ការរៀបចំវគ្គបណ្តុះបណ្តាលរំលឹកឡើងស្តីអំពីដំណើរការកសាងផែនការឃុំ សង្កាត់ក្នុងស្រុកគោលដៅរបស់ UNICEF | $18,000 | UNICEF | SP5 |
| 22 | ការរៀបចំ និងការផ្សព្វផ្សាយទិន្នន័យសម្រាប់ការកសាងផែនការថ្នាក់ក្រោមជាតិ | $108,140 | Basket | SP5 |
| 23 | ការជ្រើសរើស និងការពង្រាយទីប្រឹក្សាបច្ចេកទេសនិងមន្ត្រីកិច្ចសន្យាថ្នាក់រាជធានី ខេត្ត ចំនួន២៦៨នាក់ | $2,323,200 | Basket | SP1 |
| 24 | ការគាំទ្រកិច្ចប្រតិបត្តិការនៃ ជ.ស.ថ ឆ្នាំ២០១៤ របស់រដ្ឋបាលរាជធានី ខេត្តទាំង២៤ | $1,178,160 | Basket | SP1 |
| **ខ.** | **រដ្ឋបាលក្រុង ស្រុក ខណ្ឌ** | **$3,391,252** | | |
| 1 | ការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពជាក់លាក់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំង១៩៤ | $135,800 | Basket | SP1 |
| 2 | ការរៀបចំសិក្ខាសាលាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្តីអំពីគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការចូលរួមរបស់ប្រជាពលរដ្ឋ | $38,800 | Basket | SP1 |
| 3 | ការលើកកម្ពស់ការមុខងាររបស់ គ.ក.ស.ក ថ្នាក់ក្រុង ស្រុក ខណ្ឌទាំង១៩៤ | $160,040 | Basket, UNICEF & UNFPA | SP1, SP2 |
| 4 | ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍស្ថាប័ន | $87,300 | Basket | SP2 |
| 5 | ការពង្រឹងការចុះបញ្ជីអត្រានុកូលដ្ឋាននៅក្នុងស្រុកគោលដៅចំនួន១១ | $22,000 | UNICEF | SP2 |
| 6 | ការគាំទ្រ គ.ក.ន.ក នៅក្នុងឃុំគោលដៅចំនួន៣៤៦ | $173,520 | UNFPA | SP2 |
| 7 | ការតាមដាន ការគាំទ្របច្ចេកទេស និងប្រតិបត្តិការសម្រាប់ការងារសេវាសង្គម | $11,072 | UNFPA | SP2 |
| 8 | ការជ្រើសរើស និងការពង្រាយទីប្រឹក្សាបច្ចេកទេសនិងមន្ត្រីកិច្ចសន្យាថ្នាក់ក្រុង ស្រុក ខណ្ឌចំនួន៦១០នាក់ | $1,855,800 | Basket | SP1 |
| 9 | ការគាំទ្រកិច្ចប្រតិបត្តិការនៃ ជ.ស.ថ ឆ្នាំ២០១៤របស់ក្រុង ស្រុក ខណ្ឌ | $906,920 | Basket | SP1 |
| | **ថវិកាសរុប** | **$7,968,977** | | |

## ឧបសម្ព័ន្ធ៖ ចំណុចដៅ និងសូចនាករសំខាន់ៗ

តារាងក្របខ័ណ្ឌសមិទ្ធផលនៃផអពមានសូចនាករចំនួន១១៥ដែលប្រទាក់ក្រឡាគ្នានៅគ្រប់កម្រិត។ សូចនាករទាំងនេះត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ប្រចាំឆមាស និងរបាយការណ៍ប្រចាំឆ្នាំ។ នៅក្នុងឆ្នាំ២០១៣ បានព្យាយាមដើម្បីកាត់បន្ថយចំនួនសូចនាករទាំងនេះដែលជាផ្នែកមួយនៃកិច្ចពិភាក្សា និងកិច្ចដំណើរការក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) និងជាផ្នែកមួយក្នុងការរៀបចំកម្មវិធីប៉ាន់ស្មានរបស់សហគមន៍អឺរ៉ុប (Program Estimate)។ ចំណុចដៅចំនួន១៦នៃចំណុចដៅទាំងអស់ដែលគ្រោងអនុវត្តក្នុងឆ្នាំ២០១៤នេះមានរៀបរាប់ក្នុងតារាងខាងក្រោម។

**តារាងទី១២៖ ចំណុចដៅសំខាន់ៗសម្រាប់ឆ្នាំ២០១៤-២០១៨**

| សូចនាករ | ទិន្នន័យដើមគ្រា (ឆ្នាំ) | ជាក់ស្តែង | ចំណុចដៅ | | | | | ការអធិប្បាយ/សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | 2013 | 2014 | 2015 | 2016 | 2017 | 2018 | |
| **សន្ទស្សន៍នៃការផ្តល់សេវា និងអភិបាលកិច្ច** | | | | | | | | |
| ១. សន្ទស្សន៍នៃភាពពេញចិត្តក្នុងការផ្តល់សេវា | 65.14 (2011) | | 70.57 | 72.38 | 74.19 | 76.00 | 77.81 | ការអង្កេតអភិបាលកិច្ចមូលដ្ឋានត្រូវបានធ្វើក្នុងរយៈពេល២ឆ្នាំម្តង (២០១១, ២០១៣, ២០១៥...)។ សន្ទស្សន៍ទាំងអស់បានបែងចែកតាមភេទ។ ទិន្នន័យឆ្នាំ២០១៣ ត្រូវបានប្រមូលក្នុងត្រីមាសទី៤ ឆ្នាំ២០១៣។ ការសន្មត់ គឺចំណុចដៅនឹងកើន២៥% ដល់ឆ្នាំ២០២០ ហើយទិន្នន័យនេះបានបញ្ចូលក្នុងកម្មវិធីប៉ាន់ស្មានរបស់ EU ផងដែរ (Program Estimate)។ |
| ២. សន្ទស្សន៍អភិបាលកិច្ច | 50.75 (2011) | | 54.98 | 56.39 | 57.80 | 59.21 | 60.62 | ដូចខាងលើ |
| ៣. សន្ទស្សន៍សមត្ថភាពក្រុង ស្រុក | 44.33 (2011) | | 48.02 | 49.26 | 50.49 | 51.72 | 52.95 | ដូចខាងលើ |
| **សូចនាករនៃការអនុវត្ត/លទ្ធផលរំពឹងទុក** | | | | | | | | |
| **ការផ្ទេរមុខងារ** | | | | | | | | |
| ៤. ភាគរយបូកយោងនៃថវិកាជាតិដែលបានផ្ទេរដល់ថ្នាក់ក្រោមជាតិដែលជាលទ្ធផលនៃកិច្ចដំណើរការផ្ទេរមុខងារ | 0% | 0.00% | 0.00% | 0.90% | 1.80% | 2.70% | 3.60% | សន្ទស្សន៍វាស់វែងទំហំសេវាដែលបានផ្ទេរដល់ថ្នាក់ក្រោមជាតិ។ ចំណុចដៅអាចរកបាននៅក្នុង NSDP និងអាចសន្មត់ថាទំហំនៃមូលនិធិក្រុង ស្រុក និងឃុំ សង្កាត់ (០,៨% និង២,៨% នៃថវិកា) នឹងកើនទ្វេដងនៅឆ្នាំ២០១៨។ |

| សូចនាករ | ទិន្នន័យដើមគ្រា (ឆ្នាំ) | ជាក់ស្តែង | ចំណុចដៅ | | | | | ការអធិប្បាយ/សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | 2013 | 2014 | 2015 | 2016 | 2017 | 2018 | |
| **ការបង្កើនធនធានហិរញ្ញវត្ថុ** | | | | | | | | |
| ៥. មូលនិធិក្រុង ស្រុកគិតជាភាគរយធៀបនឹងថវិកាជាតិ | 0% | 0% | 0.8% | 0.8% | 0.8% | 0.8% | 0.8% | មូលនិធិក្រុង ស្រុកមិនទាន់បានអនុវត្តពេញលេញនៅឆ្នាំ២០១៣ ប៉ុន្តែសមាសភាគរដ្ឋបាលត្រូវបានផ្ទេរតាមរយៈថវិកាខេត្ត ។ |
| ៦. ប្រភពចំណូលផ្ទាល់របស់មូលនិធិក្រុង ស្រុកគិតជាភាគរយធៀបនឹងថវិកាជាតិ | 0% | 0.00% | 0.00% | 2.50% | 5.00% | 7.50% | 10.00% | ចំណុចដៅនៅក្នុង NSDP ។ ប្រភពចំណូលផ្ទាល់ គឺជាការផ្តល់ឱ្យក្រុង ស្រុកនូវភាពបត់បែនកាន់តែច្រើនឡើង (ស្វ័យភាពច្រើនជាងមុន) ប៉ុន្តែត្រូវពង្រឹងគណនេយ្យភាពខ្សែបណ្តោយ ។ |
| ៧. ការចំណាយបូកយោងដែលផ្តល់ដោយឧបករណ៍វិនិយោគរបស់ថ្នាក់ក្រោមជាតិ (SNIF) គិតជាលានដុល្លារ | 0 | 0 | 0 | 0 | $1.0 M | $5.0 M | $10.0 M | |
| **ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងធនធានមនុស្ស និងការលើកកម្ពស់ស្វ័យភាពឱ្យកាន់តែប្រសើរឡើង** | | | | | | | | |
| ៨. ភាគរយនៃបុគ្គលិកនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលបានវាយតម្លៃ | | | 50% | 100% | 100% | 100% | 100% | មួយផ្នែកនៃការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងធនធានមនុស្សដែលនឹងត្រូវអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៩. ភាគរយនៃនាយករដ្ឋបាលរាជធានី ខេត្តដែលជាស្ត្រី | | 1.39% | 5.11% | 8.83% | 12.56% | 16.28% | 20.00% | ចំណុចដៅនៅក្នុង NSDP នឹងឡើងដល់២០%នៅឆ្នាំ២០១៨ |
| ១០. ភាគរយនៃនាយកទីចាត់ការតាមរដ្ឋបាលរាជធានី ខេត្តដែលជាស្ត្រី | | 5.00% | 8.00% | 11.00% | 14.00% | 17.00% | 20.00% | ដូចខាងលើ |
| ១១. ភាគរយនៃនាយករដ្ឋបាលក្រុង ស្រុក ខណ្ឌដែលជាស្ត្រី | | 10.38% | 13.30% | 16.23% | 19.15% | 22.08% | 25.00% | ចំណុចដៅនៅក្នុង NSDP នឹងកើនដល់២៥%នៅឆ្នាំ២០១៨ |
| ១២. ភាគរយនៃប្រធានការិយាល័យនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលជាស្ត្រី | | 18.39% | 18.39% | 18.39% | 18.39% | 18.39% | 25.00% | ដូចខាងលើ |
| **ការពង្រឹងគណនេយ្យភាពខ្សែទទឹង និងបណ្តោយ** | | | | | | | | |

| សូចនាករ | ទិន្នន័យដើមគ្រា (ឆ្នាំ) | ជាក់ស្តែង | ចំណុចដៅ | | | | | ការអធិប្បាយ/សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | 2013 | 2014 | 2015 | 2016 | 2017 | 2018 | |
| ១៣. បូកយោងចំនួនក្រុង ស្រុកដែលវិធានផ្ទៃក្នុងត្រូវបានអនុម័តដោយក្រុមប្រឹក្សា | 0 | 0 | 0 | 20 | 185 | 185 | 185 | ក៏ជាចំណុចដៅនៅក្នុង NSDP ដែរ |
| ១៤. ភាគរយនៃរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌដែលបានធ្វើសវនកម្ម និងទទួលពិន្ទុពេញចិត្តទាក់ទងនឹង៖ អធិការកិច្ចលើការអនុវត្តតាម សវនកម្មហិរញ្ញវត្ថុ សវនកម្មលទ្ធកម្ម និងសវនកម្មគម្រោង | 0.00% | 0.00% | 0.00% | 10.00% | 20.00% | 30.00% | 40.00% | សន្មត់ថានឹងកើនដល់៦០% នៅឆ្នាំ២០២០។ ចំណុចដៅនេះក៏បានបញ្ចូលក្នុងការបាន់ស្មានកម្មវិធីរបស់ EU (Program estimate) ផងដែរ។ |
| ១៥. បូកយោងចំនួនស្រុកដែលឃុំទាំងអស់ដែលបានបំពេញនូវតម្រូវការផ្នែកគណនេយ្យភាពសង្គម | | 0 | 20 | 70 | 120 | | | សកម្មភាពទាំងឡាយរួមមាន៖ ការផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋក្នុងទម្រង់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ អនុវត្តការត្រួតពិនិត្យដោយប្រជាពលរដ្ឋ និងរៀបចំផែនការការងាររួមគ្នាអំពីគណនេយ្យភាព។ |
| **ការអនុវត្តកម្មវិធី** | | | | | | | | |
| ១៦. ភាគរយនៃលទ្ធផលសំខាន់ៗដែលសម្រេចបានតាមពេលវេលាកំណត់ | 30% (2011) | | 85% | 85% | 85% | 85% | 85% | តួលេខឆ្នាំ២០១៣នឹងត្រូវប្រមូលក្នុងខែមករាឆ្នាំ២០១៤។ |